# នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល
# នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

**សំណុំរឿងលេខ** : ០០២/១៩-០៩-២០០៧-អវតក/អជតក
**ដាក់ទៅ** : អង្គជំនុំជម្រះតុលាការកំពូល
**ថ្ងៃដាក់** : ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៣
**ភាគីអ្នកដាក់** : សហព្រះរាជអាជ្ញា
**ភាសាដើម** : អង់គ្លេស

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 17-Jun-2013, 15:32
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារកំណត់ដោយអង្គជំនុំជម្រះតុលាការកំពូល: សាធារណៈ/Public

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:

ការពិនិត្យចំណាត់ថ្នាក់ឯកសារបណ្តោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

## ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញា ទៅនឹងបណ្តឹងសាទុក្ខរបស់ នួន ជា ជំទាស់នឹងសេចក្តីសម្រេចលើកទីពីរ ស្តីពីការបំបែកកិច្ចដំណើរការនីតិវិធី និងសេចក្តីសន្និដ្ឋានតបទៅនឹងចម្លើយតបរបស់គាត់ទៅនឹងបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា

**អ្នកដាក់ឯកសារ:**
**សហព្រះរាជអាជ្ញា:**
លោកស្រី ជា លាង
លោក Andrew CAYLEY

**អ្នកទទួលឯកសារ:**
**អង្គជំនុំជម្រះតុលាការកំពូល:**
ចៅក្រម គង់ ស្រីម, ប្រធាន
ចៅក្រម A. KLONOWIECKA-MILART
ចៅក្រម សោម សិរីវឌ្ឍ
ចៅក្រម C. N. JAYASIINGHE
ចៅក្រម ម៉ុង មុន្នីចរិយា
ចៅក្រម យ៉ា ណារិន
ចៅក្រម Florence Ndepele NUMBA

**ចម្លងជូន:**
**សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី:**
ពេជ អង្គ
Elisabeth SIMONNEAU FORT

**ជនជាប់ចោទ:**
នួន ជា
ខៀវ សំផន

**មេធាវីការពារក្តីជនជាប់ចោទ:**
លោក សុន អរុណ
លោក Victor Koppe
លោក គង់ សំអុន
លោកស្រី Anta GUISSÉ
លោក Arthur VERCKEN
លោក Jacques VERGES

## I. សេចក្តីផ្តើម

១- អនុលោមតាមវិធាន១០៤, ១០៥, ១០៦(២) និង ១០៧ នៃវិធានផ្ទៃក្នុង ("វិធាន")[1] សហព្រះរាជអាជ្ញាដាក់ចម្លើយតបរួមនេះ និងសេចក្តីសន្និដ្ឋានឆ្លើយតប ("ចម្លើយតប") ទៅនឹង៖ (i) បណ្តឹងសាទុក្ខភ្លាមៗរបស់ជនជាប់ចោទ នួន ជា ("បណ្តឹងសាទុក្ខ")[2] និងសារណាបន្ថែម ជាបន្ទាប់មកទៀត ("សេចក្តីបន្ថែម")[3] ជូនអង្គជំនុំជម្រះតុលាការកំពូល("អង្គជំនុំជម្រះ") ប្រឆាំងនឹងសេចក្តីសម្រេចអង្គជំនុំជម្រះសាលាដំបូង ស្តីពីការបំបែកកិច្ចដំណើរការនីតិវិធីនៃសំណុំរឿង០០២/០១ បន្ទាប់ពីមានសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០១៣ ("សេចក្តីសម្រេចដែលរងការជំទាស់")[4] និង (ii) ទៅនឹងចម្លើយតបរបស់ជនជាប់ចោទ នួន ជា ទៅនឹងបណ្តឹងសាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញានៅចំពោះមុខអង្គជំនុំជម្រះនេះ ("បណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា")[5]។

២- អាស្រ័យមូលហេតុដូចបានបញ្ជាក់ខាងក្រោមនេះ សហព្រះរាជអាជ្ញាមិនជំទាស់ទៅនឹងភាពអាចទទួលយកបាននៃបណ្តឹសាទុក្ខខាងលើទេ ក៏ប៉ុន្តែជូនជាយោបល់ថា បណ្តឹងសាទុក្ខនេះគួរត្រូវបានបដិសេធទាំងមូល។

---

[1] អង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជា, វិធានផ្ទៃក្នុង (វិ. លើកទី ៨), ថ្ងៃទី៣ ខែសីហា ឆ្នាំ២០១១ ("វិធាន")។

[2] ឯកសារលេខ **E284/4/1** បណ្តឹងសាទុក្ខភ្លាមៗ ជំទាស់នឹងសេចក្តីសម្រេចលើកទីពីរ របស់អង្គជំនុំជម្រះសាលាដំបូងស្តីពីការបំបែកកិច្ចដំណើរការនីតិវិធី និងចម្លើយតបចំពោះបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាលើសេចក្តីសម្រេចលើកទីពីរស្តីពីការបំបែកកិច្ចដំណើរការនីតិវិធី, ចុះថ្ងៃទី២៧ ឧសភា ២០១៣ ("បណ្តឹងសាទុក្ខភ្លាមៗរបស់ នួន ជា")។

[3] ឯកសារលេខ **E284/4/2** សារណាបន្ថែមចំពោះបណ្តឹងសាទុក្ខ ជំទាស់នឹងសេចក្តីសម្រេចលើកទីពីរ របស់អង្គជំនុំជម្រះសាលាដំបូងស្តីពីការបំបែកកិច្ចដំណើរការនីតិវិធី,ចុះថ្ងៃទី៣០ មេសា ២០១៣។

[4] ឯកសារលេខ **E163/5** សេចក្តីជូនដំណឹងស្តីពីសេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាដែលស្នើសុំដាក់បញ្ចូលទីតាំងឧក្រិដ្ឋកម្មបន្ថែម នៅក្នុងវិសាលភាពនៃការជំនុំជម្រះក្នុងសំណុំរឿងលេខ០០២/០១ (ឯកសារ E163) និងពេលវេលាកំណត់នៃការដាក់សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលពាក់ព័ន្ធនឹងច្បាប់ជាធរមាន, ចុះថ្ងៃទី៨ តុលា ឆ្នាំ២០១២ (" សេចក្តីសម្រេចដែលរងការជំទាស់")។

[5] ឯកសារលេខ **E284/2/1** បណ្តឹងសាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញា ជំទាស់នឹង សេចក្តីសម្រេចលើកទីពីរ របស់អង្គជំនុំជម្រះសាលាដំបូងស្តីពីការបំបែកកិច្ចដំណើរការនីតិវិធី នៅក្នុងសំណុំរឿងលេខ០០២ ចុះថ្ងៃទី១០ ឧសាភា ២០១៣ ("បណ្តឹងសាទុក្ខជំទាស់នឹងសេចក្តីសម្រេចលើកទីពីររបស់សហព្រះរាជអាជ្ញា") ។

## II. ប្រវត្តិនីតិវិធី

៣- កាលពីថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១៣ អង្គជំនុំជម្រះសាលាដំបូងបានចេញសេចក្តីសម្រេចដែលរងការជំទាស់។ កាលពីថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១៣ បណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាត្រូវបានដាក់ជូនអង្គជំនុំជម្រះនេះ។ នៅថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៣ មេធាវីការពារក្តីរបស់ជនជាប់ចោទ នួន ជា ("មេធាវីការពារក្តី") បានស្នើសុំ និងបានទទួលការអនុញ្ញាតឲ្យដាក់បណ្តឹងសាទុក្ខភ្លាមៗតែជាភាសាអង់គ្លេសប៉ុណ្ណោះ មិនឲ្យហួសពីថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១៣។ បណ្តឹងសាទុក្ខនេះត្រូវបានដាក់ទាន់ពេលកំណត់ ប៉ុន្តែបានជូនដំណឹងដល់ភាគីនានា នៅថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៣ ហើយអត្ថបទជាភាសាខ្មែរត្រូវបានជូនដំណឹងដល់ភាគីនៅថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០១៣។ សេចក្តីបន្ថែមត្រូវបានដាក់ជាភាសាខ្មែរ និងភាសាអង់គ្លេស នៅថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៣។

៤- កាលពីថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០១៣ សហព្រះរាជអាជ្ញាបានស្នើសុំ និងបានទទួលការអនុញ្ញាតឲ្យដាក់នូវចម្លើយតបរួមនេះ។ អនុលោមតាមមាត្រា៨.៣ នៃសេចក្តីណែនាំអនុវត្តជាធរមាន[6] ចម្លើយតបបច្ចុប្បន្ននេះជាភាសាអង់គ្លេស និងជាភាសាខ្មែរ ត្រូវបានដាក់ នៅក្នុងពេលយ៉ាងយូរ១០ថ្ងៃតាមប្រក្រតិទិន ដោយគិតចាប់តាំងពីកាលបរិច្ឆេទនៃការជូនដំណឹងអត្ថបទជាភាសាខ្មែរនៃបណ្តឹងសាទុក្ខ។

## III. អំពីភាពអាចទទួលយកបាន

៥- សហព្រះរាជអាជ្ញាមិនជំទាស់អំពីភាពអាចទទួលយកបាននៃបណ្តឹងសាទុក្ខនេះទេ។ កាលពីមុន អង្គជំនុំជម្រះនេះបានសម្រេចថា ការបំបែកកិច្ចដំណើរការនីតិវិធីនៃការចោទប្រកាន់នានា នៅក្នុងកាលៈទេសៈដែលលទ្ធភាពនៃការជំនុំជម្រះនាពេលខាងមុខចំពោះការចោទប្រកាន់ នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលនៅសេសសល់ គឺនៅឆ្ងាយមិនអាចមើលឃើញឡើយ ស្មើនឹងការបញ្ចប់កិច្ចដំណើរការនីតិវិធីដោយប្រសិទ្ធភាពទាក់ទងទៅនឹងការចោទប្រកាន់ទាំងនេះ ហើយហេតុដូចនេះ គឺជាកម្មវត្ថុនៃបណ្តឹងសាទុក្ខភ្លាមៗ ដោយផ្អែកលើមូលដ្ឋាននៃវិធាន១០៤(៤)(ក)នៃវិធានផ្ទៃក្នុង[7]។

---

[6] អង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជា, សេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារនៅចំពោះមុខ អវតក (វិ. លើកទី ៨), ថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១២ ។

[7] ឯកសារលេខ **E163/5/1/13** សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញាជំទាស់ទៅនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ទាក់ទងនឹងវិសាលភាពនៃសំណុំរឿងលេខ០០២/០១, ចុះថ្ងៃទី៨ កុម្ភៈ ២០១៣ ត្រង់កថាខណ្ឌទី២២ និង២៥ (" សេចក្តី

## IV. អំពីអង្គសេចក្តី

### ក) មេធាវីការពារក្តីត្រូវបានរារាំងមិនឱ្យលើកឡើងអំពីភាពមិនត្រឹមត្រូវនៃការបំបែកកិច្ចដំណើរការនីតិវិធី

៦- ជាគោលការណ៍ទូទៅនៃច្បាប់ថា ភាគីមួយមិនអាចទទួលបាននូវផលប្រយោជន៍ ក្នុងការលើកអំណះអំណាងមុនគេ ដោយមិនស៊ីសង្វាក់គ្នាជាមួយនឹងអំណះអំណាងពីមុនៗរបស់ភាគីនោះឡើយ (*allegans contraria non audiendus est)* [8]។ គោលការណ៍នេះបានរកឃើញនូវការសំដែងចេញដោយផ្ទាល់នៅក្នុងប្រព័ន្ធច្បាប់ស៊ីវិល និងប្រព័ន្ធច្បាប់អង់គ្លោសាក់សុង ទាំងមូល[9] ក៏ដូចជា នៅចំពោះមុខតុលាការឧក្រិដ្ឋកម្មអន្តរជាតិនានា[10] និងតុលាការយុត្តិធម៌អន្តរជាតិ នៅក្នុងសាលក្រមមួយដែល

---

សម្រេចលើបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាស្តីពីវិសាលភាព")។ សូមអានផងដែរ ឯកសារលេខ **E138/1/7** សេចក្តីសម្រេច លើបណ្តឹងសាទុក្ខភ្លាមៗប្រឆាំងនឹងដីកាសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងការដោះលែងជនជាប់ចោទ អៀង ធីរិទ្ធ, ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១១ ត្រង់កថាខណ្ឌទី១៥។ ឯកសារលេខ **E51/15/1/2.1** មតិជំទាស់របស់លោកចៅក្រម Klonowiecka-Milart និងលោកចៅក្រម Jayasinge ចំពោះ "សេចក្តីសម្រេចលើបណ្តឹងសាទុក្ខរបស់ អៀង សារី ជំទាស់នឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើអញ្ញត្រកម្មបឋមរបស់ អៀង សារី អនុលោមតាមវិធាន៨៩ (*ហាមកាត់ក្តីពីរដងលើបទល្មើសតែមួយដដែល Ne Bis In Idem* និងការលើកលែងទោស និងអនុគ្រោះទោស)", ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០១២ ត្រង់កថាខណ្ឌទី១ (ដែលច្រានចោលនូវ "សំណើដែលមិនបាននិយាយឱ្យច្បាស់ៗថា យុត្តាធិការរបស់អង្គជំនុំជម្រះនេះ លើបណ្តឹងសាទុក្ខភ្លាមៗ គឺត្រូវបានកំរិតត្រឹមតែ កាលៈទេសៈដ៏តូចចង្អៀតដូចដែលបានចុះក្នុងបញ្ជី នៅក្នុងវិធាន១០៤(៤)នៃវិធានផ្ទៃក្នុង។

[8] សូមអាន ឧទា. *ក្នុងករណីរឿងក្តីរបស់ Cairncross ទល់នឹង Lorimer* (ឆ្នាំ១៨៦០) 3 Macq 827, ដែលទទួលស្គាល់នូវទ្រឹស្តី ដែលមានឬសគល់ដូចគ្នា ស្តីពី "ការហាមឃាត់បុគ្គល" នៅក្នុងច្បាប់របស់ប្រទេសស្កុតលែន ដែលជាផ្នែកនៃ " ច្បាប់របស់ប្រជាជាតិដែលមានអារ្យធម៌ជឿនលឿន"។

[9] សូមអាន ឧទា. *ករណីរឿងក្តីរបស់ Boizard (Liselotte) ទល់នឹង Commission of the European Communities* [ឆ្នាំ១៩៨២] 1 CMLR 157, តាម Advocate General Warner at 171: "ចំពោះខ្ញុំ ហាក់ដូចជាថា , បើសិនជាគេពិចារណា , ឧទាហរណ៍ដូចជា, ច្បាប់របស់ប្រទេសដាណឺម៉ាក ដូចជា 'stiltiende afkald', ច្បាប់របស់អង់គ្លេស ដូចជា ច្បាប់ដែលហាមមិនឱ្យភាគីណាមួយបដិសេធសកម្មភាពណាមួយដែលខ្លួនបានប្រព្រឹត្ត( estoppel), ច្បាប់របស់ប្រទេសអាល្លឺម៉ង់ ដូចជា 'Rechtsverwirkung', ច្បាប់របស់ប្រទេសអ៊ីតាលី ដូចជា 'legittimo affidamento' និងច្បាប់របស់ប្រទេសស្កុតឡែន ដូចជា ការហាមឃាត់បុគ្គល(personal bar), ក៏ដូចជាច្បាប់របស់បារាំង ដូចជា 'ការបដិសេធដោយមិនបាននិយាយឱ្យច្បាស់ (renonciation implicite)', ដែលនៅក្នុងច្បាប់ទាំងនេះសុទ្ធតែលេចឡើងនូវគោលការណ៍ទូទៅមួយ..."។

[10] សូមអាន ឧទា.*ករណីរឿងក្តីរបស់ រដ្ឋអាជ្ញា ទល់នឹង Bizimungu,* សំណុំរឿងលេខ ICTR-99-50-T, សេចក្តីសម្រេចលើញត្តិរបស់មេធាវីការពារក្តីដែលស្នើសុំ ឱ្យពិនិត្យឡើងវិញនូវដីកាសម្រេចចុះថ្ងៃទី២ ខែមិថុនា ឆ្នាំ២០០៨ ដែលបដិសេធមិនទទួលយកនូវកំណត់ហេតុរបស់ព្រះវិហារ និង សាលារៀន (អង្គជំនុំជម្រះសាលាដំបូងទីII នៃតុលាការ ICTR), ចុះថ្ងៃទី២៣ កក្កដា ២០០៨ ត្រង់កថាខណ្ឌ៩ ចច ( ដែលបានយកមកអនុវត្តនូវគោលការណ៍របស់ ប្រព័ន្ធច្បាប់អង់គ្លោសាក់សុង ស្តីពីបញ្ហាការ ហាមមិនឱ្យភាគីណាមួយបដិសេធអំពើណាមួយដែលខ្លួនបានប្រព្រឹត្ត)។ *ករណីរឿងក្តីរបស់ រដ្ឋអាជ្ញា ទល់នឹង µdouard Karemera, Mathieu Ngirumpatse និង Joseph Nzirorera,* សំណុំរឿងលេខ ICTR-98-44-T, សេចក្តីសម្រេចលើញត្តិរបស់ Joseph Nzirorera ដែលស្នើសុំឱ្យវាយបកទៅនឹងការចោទប្រកាន់អំពីការរួម

ចងកាតព្វកិច្ចជាក់លាក់ចំពោះព្រះរាជាណាចក្រកម្ពុជា[11]។ សហព្រះរាជអាជ្ញាមិនស្នើសុំឲ្យយកគោលការណ៍ *ហាមឃាត់មិនឲ្យភាគីណាមួយផ្តល់ចម្លើយដែលផ្ទុយពីអ្វី ដែលខ្លួនបានប្រកាសរួចកាលពីមុន ដែលនាំឲ្យមានផលប៉ះពាល់ដល់កិច្ចដំណើរការនីតិវិធី*[12] តាមប្រព័ន្ធច្បាប់បែបអង់គ្លេសាក់សុង មកអនុវត្តតាមទាំងស្រុង នៅចំពោះមុខ អវតក នោះឡើយ[13] ក៏ប៉ុន្តែ ផ្ទុយទៅវិញ ជូនជាមតិថា គោលការណ៍ជាមូលដ្ឋាន *ការផ្តល់ចម្លើយដែលផ្ទុយពីចម្លើយមុន* គឺជាផ្នែកមួយត្រឹមត្រូវនៃច្បាប់ជាធរមាន ហើយដែលស្របគ្នាទាំងស្រុងជាមួយនឹងប្រព័ន្ធច្បាប់របស់កម្ពុជា។ គោលការណ៍ដែលដំណើរការនៅទីនេះ គឺដើម្បីហាមឃាត់មេធាវីការពារក្តីមិនឲ្យលើកឡើងតទៅទៀតនូវអំណះអំណាងដែលថា អង្គជំនុំជម្រះសាលាដំបូងបានប្រព្រឹត្តខុសក្នុងការសម្រេចជ្រើសយកនូវទម្រង់*ណាមួយ* នៃការបំបែកកិច្ចដំណើរការនីតិវិធី[14] ឬថានីតិវិធីនៃការបំបែកកិច្ចដំណើរការនីតិវិធីមានជំហរប្រឆាំងទៅនឹងសិទ្ធិជាមូលដ្ឋានក្នុងការទទួលបាននូវការជំនុំជម្រះក្តីដោយត្រឹមត្រូវ[15] ដោយកាលពីមុនបានប្រកាន់យកជាបន្តទៅទៀតនូវគោលជំហរមិនស្របគ្នាដែលមិនអាចសម្របសម្រួលបាន នៅក្នុងដំណើរការនីតិវិធីរបស់តុលាការក្នុងសំណុំរឿងលេខ០០២។

៧- ចាប់តាំងពីពេលដែលការបំបែកកិច្ចដំណើរការនីតិវិធីត្រូវបានចេញជាលើកទីមួយ នៅក្នុងខែកញ្ញា ឆ្នាំ ២០១១មក មេធាវីការពារក្តីបានបន្តប្រកាន់នូវគោលជំហរដែលផ្ទុយគ្នាទាំងស្រុង ទៅនឹងសេចក្តីសន្និដ្ឋានដែលមាននៅក្នុងបណ្តឹងសាទុក្ខភ្លាមៗនេះ - ដែលនិយាយថាការបំបែកកិច្ចដំណើរការនីតិវិធី

---

គំនិតគ្នាជាមួយ Juvenal Kajelijeli ដោយផ្អែកលើមូលដ្ឋាននៃគោលការណ៍ មិនទទួលបណ្តឹងជាថ្មី , ចុះថ្ងៃទី១៦ កក្កដា ២០០៨ (ដែលពិនិត្យទៅលើគោលការណ៍ មិនទទួលបណ្តឹងជាថ្មី របស់ប្រព័ន្ធច្បាប់របស់អង់គ្លេសាក់សុង ប៉ុន្តែរកឃើញថាមិនអាចយកមកអនុវត្តទៅលើអង្គហេតុបាន)។

[11] រឿងប្រាសាទព្រះវិហារ *(ករណីរឿងក្តីរបស់ប្រទេសកម្ពុជា ទល់នឹងប្រទេសថៃឡង់) (អង្គសេចក្តី)* [ឆ្នាំ១៩៦២] ICJ Rep 6, 39 (យោបល់ដាច់ដោយឡែករបស់លោកចៅក្រម Alfaro)។ សូមអានផងដែរ តំបន់ខ្ពង់រាបជាប់ដីគោកនៃសមុទ្រខាងជើង (*ករណីរឿងក្តីរបស់ប្រទេសដាណឺម៉ាក ទល់នឹង សាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់*)។ *ករណីរឿងក្តីរបស់ប្រទេស ហុល្លង់ ទល់នឹង សាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់*) [ឆ្នាំ១៩៦៩] ICJ Rep 4, 120 (យោបល់ដាច់ដោយឡែករបស់លោកចៅក្រម Ammoun)។

[12] សូមអាន ឧទា. ករណីរឿងក្តីរបស់រដ្ឋ *New Hampshire ទល់នឹង រដ្ឋ Maine,* សំណុំរឿងលេខ 532 U.S. 742 (ឆ្នាំ 2001)។ *In re Kane,* 628 F.3d 631, 638-40 (3d Cir. 2010).

[13] សូមអាន ឧទា. ឯកសារលេខ E96/6 ត្រង់កថាខណ្ឌទី២៧, ដែលសហព្រះរាជអាជ្ញា បានលើកឡើងថា “ទស្សនាទានស្តីពីគោលការណ៍ស្តីពី ហាមឃាត់មិនឲ្យភាគីណាមួយផ្តល់ចម្លើយដែលផ្ទុយពីអ្វីដែលខ្លួនបានប្រកាសរួចកាលពីមុន (concept of estoppel) គេមិនដែលធ្លាប់ស្គាល់ទេ នៅក្នុងប្រព័ន្ធច្បាប់កម្ពុជា ឬ នៅក្នុងច្បាប់នៀមទម្លាប់របស់ប្រព័ន្ធច្បាប់ស៊ីវិល និយាយឲ្យទូលាយជាងនេះ”។

[14] ឯកសារលេខ **E284/4/1** បណ្តឹងសាទុក្ខភ្លាមៗរបស់ នួន ជា, កំនត់សម្គាល់លេខ២ ត្រង់កថាខណ្ឌទី៩។

[15] ឯកសារលេខ **E284/4/1** *ដូចគ្នានឹងខាងលើ* ត្រង់កថាខណ្ឌពីទី១២-២១។

គឺមិនគ្រាន់តែស្របគ្នាទៅនឹងសិទ្ធិរបស់ជនជាប់ចោទប៉ុណ្ណោះទេ ក៏ប៉ុន្តែថែមទាំង*ត្រឹមត្រូវ* ក្រោមកាលៈទេសៈទៀតផង។ នៅក្នុងពេលដែលសហព្រះរាជអាជ្ញាស្វែងរកសុំដាក់បញ្ចូលនូវតំណាង សមហេតុសមផលសម្រាប់វគ្គនៃការចោទប្រកាន់នៅក្នុងសំណុំរឿងលេខ០០២/០១ បន្ទាប់ពីការបំបែកកិច្ចដំណើរការនីតិវិធី[16] មេធាវីការពារក្ដី "បានជម្រុញឲ្យអង្គជំនុំជម្រះសាលាដំបូង បន្តប្រកាន់យកនូវគោលជំហរតាមលក្ខខណ្ឌបច្ចុប្បន្ន នៅក្នុងដីកាសម្រេចស្ដីពីការបំបែកកិច្ចដំណើរការនីតិវិធីដដែល-ដោយពុំមានការមន្ទិលសង្ស័យណាមួយថា សេចក្ដីសម្រេចមានលក្ខណៈគួរឲ្យរសើបបំផុតលេចចេញពី អវតក និងថាសេចក្ដីសម្រេចនោះ គួរតែត្រូវបានធ្វើឡើងដោយ កសចស តាំងពីឆ្នាំ២០០៧ មកម្ល៉េះ"[17]។ មេធាវីការពារក្ដីបានបន្តប្រកាន់យកនូវគោលជំហរមួយដែលជំទាស់ទៅនឹងសហព្រះរាជអាជ្ញា-ដោយជោគជ័យនៅក្នុងកាលៈទេសៈពិសេសនោះ[18]- អង្គជំនុំជម្រះមិនគួរស្ដាប់*ចម្លើយរបស់អ្នកដែលជាប់ពាក់ព័ន្ធជាសាច់ញាតិទេ* (non audiendus) - អំណះអំណាងដែលឥឡូវនេះកំពុងតែបន្តប្រកាន់យកនូវជំហរដែលមិនស្របគ្នា និងដែលមិនអាចសម្របសម្រួលបាន។ មេធាវីការពារក្ដីបានគាំទ្រយ៉ាងពេញទំហឹងដល់ភាពត្រឹមត្រូវនៃការបំបែកកិច្ចដំណើរការនីតិវិធី និងជំទាស់ទៅនឹងការព្យាយាមរបស់សហព្រះរាជអាជ្ញា ដើម្បីជួសជុលកំហុសដែលកើតចេញពីការបំបែកកិច្ចដំណើរការនីតិវិធីនេះ ដែលក្នុងនោះរួមមាន ការព្យាយាមធ្វើជាខែលបិទបាំងការបំបែកកិច្ចដំណើរការនីតិវិធី ក្នុងសំណុំរឿងលេខ០០២ មិនឲ្យមានការពិនិត្យឡើងវិញរបស់អង្គជំនុំជម្រះតុលាការកំពូល[19]។ ឥឡូវនេះ មេធាវីការពារក្ដីមិនអាចស្វែងរកដំណោះស្រាយតាមការប្ដឹងសាទុក្ខដោយស្របតាមច្បាប់ ដោយប្រកាន់យកគោលជំហរជំទាស់ នៅក្នុងដំណាក់កាលចុងក្រោយនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះនេះបានឡើយ។

---

[16] ឯកសារលេខ **E124/2** សំណើរបស់សហព្រះរាជអាជ្ញា សុំឲ្យពិចារណាឡើងវិញលើ " ដីកាសម្រេចស្ដីពីការបំបែកកិច្ចដំណើរការនីតិវិធីអនុលោមតាមវិធាន ៨៩ស្ទួនពីរ នៃវិធានផ្ទៃក្នុង, ចុះថ្ងៃទី៣ តុលា ២០១១ (" សំណើសុំឲ្យពិនិត្យឡើងវិញ")។

[17] ឯកសារលេខ **E124/5** ចម្លើយតបទៅនឹងសំណើរបស់សហព្រះរាជអាជ្ញា "សុំឲ្យពិនិត្យឡើងវិញលើដីកាសម្រេចស្ដីពីការបំបែកកិច្ចដំណើរការនីតិវិធី, ចុះថ្ងៃទី១១ តុលា ២០១១ ត្រង់កថាខណ្ឌទី៣ (" ចម្លើយតបទៅនឹង សំណើរបស់សហព្រះរាជអាជ្ញាដែលសុំឲ្យពិនិត្យឡើងវិញ")។

[18] ឯកសារលេខ **E124/7** សេចក្ដីសម្រេច លើ" សំណើរបស់សហព្រះរាជអាជ្ញា សុំឲ្យពិចារណាឡើងវិញ លើលក្ខខណ្ឌ នៃដីកាសម្រេចស្ដីពីការបំបែកកិច្ចដំណើរការនីតិវិធីរបស់អង្គជំនុំជម្រះសាលាដំបូង (ឯកសារលេខ E124/2) និងញត្តិ និងឧបសម្ព័ន្ធដែលពាក់ព័ន្ធ, ចុះថ្ងៃទី១៨ តុលា ២០១១។

[19] សូមអាន ឯកសារលេខ **E163/5/1/4** ចម្លើយតបទៅនឹងបណ្ដឹងសាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញាជំទាស់នឹងសេចក្ដីសម្រេចទាក់ទងនឹងវិសាលភាពនៃការជំនុំជម្រះក្ដីក្នុងសំណុំរឿងលេខ០០២/០១, ចុះថ្ងៃទី១៩ វិច្ឆិកា២០១២ (" ចម្លើយតបទៅនឹងបណ្ដឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា អំពីវិសាលភាព")។

### *(ខ) ការបំបែកកិច្ចដំណើរការនីតិវិធីនៃសំណុំរឿងលេខ០០២ គឺស្របគ្នាទាំងស្រុងជាមួយនឹងសិទ្ធិក្នុងការទទួលបាននូវការជំនុំជម្រះក្តីដោយត្រឹមត្រូវរបស់ជនជាប់ចោទ*

៨- មេធាវីការពារក្តីខកខានមិនបានគាំទ្រប្រកបដោយអត្ថន័យ ចំពោះអំណះអំណាងរបស់ខ្លួនដែលថា ការបំបែកកិច្ចដំណើរការនីតិវិធីអាចរំលោភទៅលើសិទ្ធិក្នុងការទទួលបាននូវការជំនុំជម្រះក្តីដោយត្រឹមត្រូវរបស់ជនជាប់ចោទ។ សំដីដំបូងនៅក្នុងអំណះអំណាងរបស់មេធាវីការពារក្តី គឺថា សិទ្ធិក្នុងការទទួលបានការជំនុំជម្រះក្តីដោយត្រឹមត្រូវរបស់ជនជាប់ចោទ គឺអាស្រ័យទៅលើការប្រឈមនឹងគ្រប់ការចោទប្រកាន់ទាំងអស់ដែលប្រឆាំងនឹងរូបគាត់ ហើយដូចនេះថា សំណុំរឿងលេខ០០២ "ត្រូវបានពិនិត្យពិចារណាទាំងមូល"[20] ពីព្រោះ"គោលនយោបាយដែល នួន ជា ត្រូវបានចោទប្រកាន់ថាបានអនុវត្តនៅក្នុងសំណុំរឿងលេខ០០២/០១នោះ គឺជាផ្នែកមួយនៃការខិតខំប្រឹងប្រែងធំជាង ដើម្បីធ្វើឲ្យមានសណ្តាប់ធ្នាប់ឡើងវិញដល់ប្រទេសជាតិ និងដល់សេដ្ឋកិច្ចដែលត្រូវបានបំផ្លិចបំផ្លាញខ្ទេចខ្ទីរទាំងស្រុងដោយសារសង្គ្រាម និងធ្វើឲ្យមានឯករាជ្យភាពដល់ប្រជាជនដែលត្រូវបានដាក់ឲ្យស្ថិតនៅក្រោមការគ្រប់គ្រងរបស់បរទេសដែលមកកាន់កាប់ និងប្រទេសមហាអំណាចដែលជាអាណានិគម អស់រយៈពេលជាច្រើនឆ្នាំ"[21]។ មេធាវីការពារក្តីបានផ្តល់នូវការចង្អុលបង្ហាញភស្តុតាងទាក់ទងអង្គហេតុ និងអង្គច្បាប់តិចតួចបំផុត សម្រាប់ការចោទប្រកាន់របស់ខ្លួនចំពោះការរំលោភលើសិទ្ធរបស់ជនជាប់ចោទ ហើយជាសំខាន់បានពឹងផ្អែកលើការដកស្រង់សេចក្តីពីក្នុងសារណារបស់ខ្លួនផ្ទាល់ដែលបានដាក់ជូនអង្គជំនុំជម្រះសាលាដំបូង នៅក្នុងពេលសវនាការស្តីពីការបំបែកកិច្ចដំណើរការនីតិវិធី[22]។

៩- ការអះអាងរបស់មេធាវីការពារក្តីថា ការបំបែកកិច្ចដំណើរការនីតិវិធីបានធ្វើឲ្យខូចត្រឹមកម្រិតណាមួយដល់សិទ្ធិរបស់ជនជាប់ចោទ ក្នុងការតទល់គ្នាជាមួយនឹងសាក្សីដែលប្រឆាំងនឹងរូបគាត់នោះ គឺមិនមានមូលដ្ឋានត្រឹមត្រូវទេ។ មេធាវីការពារក្តីត្រូវបានអនុញ្ញាតឲ្យតាំងសំណួរចំពោះសាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីគ្រប់រូបដែលបានផ្តល់សក្ខីកម្មនៅចំពោះមុខតុលាការ នៅក្នុងសំណុំរឿងលេខ ០០២/០១។ មានការបញ្ជាក់យ៉ាងច្បាស់លាស់តាំងពីដំបូងហើយថា ការបន្ថែមពីលើព្រឹត្តិការណ៍នៃឧក្រិដ្ឋកម្មសំខាន់ៗ ដែលបានចោទប្រកាន់នៅក្នុងសំណុំរឿងលេខ០០២/០១ វិសាលភាពនៃសំណុំរឿងលេខ០០២/០១ បានដាក់បញ្ចូលប្រវត្តិដើម និងរចនាសម្ព័ន្ធរដ្ឋបាល, ការប្រាស្រ័យទាក់ទង,

---

[20] ឯកសារ **E284/4/1** បណ្តឹងសាទុក្ខឧទ្ធរណ៍របស់ នួន ជា, កំណត់សម្គាល់លេខ ២ *ខាងដើម* ត្រង់កថាខណ្ឌទី១៣។

[21] ឯកសារលេខ **E284/4/1** *ដូចគ្នានឹងខាងលើ*។

[22] ឯកសារលេខ **E284/4/1** *ដូចគ្នានឹងខាងលើ*។

និងឃោធា[23] និងថាគ្រប់ភាគីទាំងអស់អាចដាក់នូវភ័ស្តុតាង និងសួរសំណួរសាក្សី លើវិស័យទាំងនេះបាន។ មួយផ្នែកនៃមូលហេតុសម្រាប់ដាក់បញ្ចូលបញ្ហាទាំងនេះ នៅក្នុងដំណាក់កាលដំបូងនៃការជំនុំជម្រះ ក្នុងសំណុំរឿងលេខ០០២/០១ គឺមានបំណងផ្តល់នូវមូលដ្ឋានគ្រឹះសម្រាប់ការជំនុំជម្រះការចោទប្រកាន់ទាំងអស់ចំពោះជនជាប់ចោទ ទាំងនៅក្នុងការជំនុំជម្រះនាពេលបច្ចុប្បន្ន និងនាពេលអនាគត ដូច្នេះ គឺមានន័យថា មុនពេលចាប់ផ្តើមដំណើរការនីតិវិធីលើភ័ស្តុតាងនៅក្នុងសំណុំរឿងលេខ០០២/០១។ អង្គជំនុំជម្រះសាលាដំបូងបានណែនាំភាគីថា ទោះបីជាមានដីកាសម្រេចស្តីពីការបំបែកកិច្ចដំណើរការនីតិវិធីកាលពីខែកញ្ញា ឆ្នាំ២០១១ ក៏ដោយ "ក៏ជនជាប់ចោទត្រូវតែតទល់ជាមួយនឹងការចោទប្រកាន់ទាំងអស់ដែលមាននៅក្នុងដីកាដំណោះស្រាយសំណុំរឿងលេខ០០២"[24]។ ប្រសិនបើមេធាវីការពារក្តីទាមទារថាមិនប្រើប្រាស់ភ័ស្តុតាងពាក់ព័ន្ធនឹងផ្នែកខ្លះនៃផ្នែកទាំងនេះ ដោយសារមេធាវីការពារក្តីបានចាត់ទុកថានេះជា"ការប្រើប្រាស់ដោយកង្វះយុទ្ធសាស្ត្រចំពោះពេលវេលាបែងចែកឲ្យខាងមេធាវីការពារក្តី"[25] នោះគឺជាសិទ្ធិជ្រើសរើសរបស់កូនក្តីខ្លួន ប៉ុន្តែមិនមែនជាការរំលោភលើសិទ្ធិរបស់ជនជាប់ចោទទេ។

១០- មេធាវីការពារក្តីបានដឹងយ៉ាងច្បាស់ថា ប្រធានបទទាំងនេះបានបង្កើតទៅជាផ្នែកមួយនៃកំណត់ហេតុភ័ស្តុតាង ទោះបីជាមានការគាំទ្រនៅត្រង់ចំណុចណាមួយថា ភ័ស្តុតាងដែលប្រមូលបានមកដល់ពេលនេះ នៅក្នុងសំណុំរឿងលេខ០០២/០១ ដែលទាក់ទងទៅនឹងមន្ទីរសន្តិសុខស-២១ និងទីកន្លែងសម្លាប់មនុស្សនៅក្នុងស្រុក១២ ប្រសិនបើមិនត្រូវបានប្រើប្រាស់នៅក្នុងការចោទប្រកាន់ដោយផ្ទាល់ប្រឆាំងនឹងជនជាប់ចោទនៅក្នុងសវនាការពេលនេះទេ "អាចត្រូវបានប្រើដោយអង្គជំនុំជម្រះសាលាដំបូង នៅក្នុងពេលសម្រេចសាលក្រមមួយ ការពិតសម្រាប់គោលបំណងវាយតម្លៃចំពោះប្រធានបទជាច្រើនដែលខុស នៅក្នុងសំណុំរឿងលេខ០០២ រួមមាន ប្រវត្តិសាស្ត្រ, រចនាសម្ព័ន្ធរដ្ឋបាល និងការប្រាស្រ័យទាក់ទងរបស់ បកក និងរបបកម្ពុជាប្រជាធិបតេយ្យ, តួនាទី និងមុខតំណែងរបស់ជនជាប់ចោទ"

---

[23] ឯកសារលេខ **E124/7.3** បញ្ជីកថាខណ្ឌ និងផ្នែកនៃដីកាដំណោះស្រាយដែលពាក់ព័ន្ធនឹងសំណុំរឿងលេខ០០២/០១ ដែលត្រូវបានកែប្រែបន្ថែមទៀត ពីលើសេចក្តីសម្រេចរបស់អង្គជំនុំជម្រះលាលាដំបូង លើបញ្ហាកាយសម្បទា និងសម្បទាខាងប្រាជ្ញាស្មារតីរបស់អៀង ធីរិទ្ធ ដើម្បីចូលរួមសវនាការ ( ឯកសារ E138) និង សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើសំណើរបស់សហព្រះរាជអាជ្ញាសុំឲ្យដាក់បញ្ចូលបន្ថែមនូវទីតាំងឧក្រិដ្ឋកម្មមួយចំនួននៅក្នុង វិសាលភាពនៃការជំនុំជម្រះក្តីក្នុងសំណុំរឿងលេខ០០២/០១ (ឯកសារ E163), ចុះថ្ងៃទី១៨ តុលា ២០១១ ត្រង់ផ្នែកទី១ ("ការរកឃើញខាងអង្គហេតុ")។

[24] ឯកសារ **E131** ដីកាសម្រេចស្តីពីការកំណត់កាលបរិច្ឆេទសម្រាប់ការធ្វើសេចក្តីសន្និដ្ឋានបើកការចោទប្រកាន់ និង សវនាការលើអង្គសេចក្តីនៅក្នុងសំណុំរៀងលេខ០០២ ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១១។

[25] ឯកសារ **E284/4/1** បណ្តឹងសាទុក្ខភ្លាមៗរបស់ នួន ជា, កំណត់សម្គាល់លេខ ២ *ខាងដើម* ត្រង់កថាខណ្ឌទី១៩។

ក៏ដូចជាការវិវឌ្ឍន៍រីកចម្រើននៃគោលនយោបាយឧក្រិដ្ឋទាំងប្រាំ ដែលបានចោទប្រកាន់ នៅក្នុងដីកាដំណោះស្រាយ។ ហេតុដូចនេះ ភ័ស្តុតាងនេះនឹងមិនត្រូវបាត់បង់តាមបែបណាមួយបានឡើយ"[26]។

១១- អំណះអំណាងរបស់មេធាវីការពារក្តីដែលថា សំណុំរឿង០០២/០១ គឺជា "ឱកាសរបស់គាត់តែមួយប៉ុណ្ណោះ ដើម្បីបង្ហាញការការពារខ្លួនគាត់ទៅនឹងការចោទប្រកាន់នៅក្នុងដីកាដំណោះស្រាយ និងសម្រាប់ឱ្យសាធារណជនកម្ពុជាបានស្តាប់អំពីការពិតនៃប្រវត្តិសាស្ត្រ ក្នុងរយៈពេលថ្មីៗនេះ"[27] គឺជាអារម្មណ៍មួយ មិនមែនជាច្បាប់ ជាទឡ្ហីករណ៍ និងមិនប៉ះពាល់ដល់សិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបានការជំនុំជម្រះត្រឹមត្រូវ។ ដោយការហួសចិត្ត ទាក់ទងនឹងការអះអាងបច្ចុប្បន្នរបស់មេធាវីការពារក្តី ចំពោះសិទ្ធិដែលគ្មានទ្រង់ទ្រាយពិតប្រាកដ ក្នុងការ "កែតម្រូវកំណត់ហេតុសាធារណៈ"[28] ទាក់ទងនឹងជនជាប់ចោទ មេធាវីការពារក្តីធ្លាប់បានបញ្ចេញមតិពីមុន នៅក្នុងការការពារការបំបែកកិច្ចដំណើរការនីតិវិធីថា "គ្រប់ភាគីទាំងអស់គួរតែធ្វើការដោយល្អ ដើម្បីរំលឹកឡើងវិញថា អវតក ត្រូវតែចូលរួមនៅក្នុងការកាត់សេចក្តីមួយ ជាជាងការព្យាយាមសរសេរប្រវត្តិសាស្ត្រ"[29]។

១២- លើសពីនេះ ទាក់ទងនឹងការអះអាងដែលថា សិទ្ធិរបស់ជនជាប់ចោទអាចត្រូវរំលោភ បើគេមិនបានយកបទចោទនៅក្នុងដីកាដំណោះស្រាយមកធ្វើការជំនុំជម្រះប្រឆាំងនឹងគាត់នៅក្នុងសវនាការ នោះជាការច្បាស់ណាស់ថា សច្ចធារណ៍នៃនិរទោសអនុវត្តចំពោះបទចោទណាមួយ រហូតទាល់តែមានការការផ្តន្ទាទោសជាក់ស្តែងណាមួយលើបទចោទនីមួយទាំងនោះ[30] គោលការណ៍មួយដែលអង្គជំនុំជម្រះខ្លួនឯងធ្លាប់បានថ្លែងយ៉ាងច្បាស់លាស់ថា "ជាគោលការណ៍សារវ័ន្តនៃកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌ ដែលជនជាប់ចោទត្រូវបានសន្មតជាមុនថាគ្មានទោស រហូតដល់តុលាការរកឃើញពីពិរុទ្ធភាព"[31]។ កិច្ចស៊ើបសួរមិនបានបង្កើតឱ្យមានការទទួលខុសត្រូវខាងព្រហ្មទណ្ឌទេ ហើយដូចនេះ ការណ៍នេះមិនអាចជាមូលដ្ឋានសម្រាប់អះអាងថាមានការរំលោភលើសិទ្ធិរបស់ជនជាប់ចោទបានទេ។

---

[26] ឯកសារលេខ **E163/5/1/4** ចម្លើយតបទៅនឹងបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាអំពីវិសាលភាព, កំណត់សម្គាល់លេខ ១៩ *ខាងដើម* ត្រង់កថាខណ្ឌទី៣៥ ( ការដកស្រង់សំដីផ្ទៃក្នុង និងការលើកសម្លាង ត្រូវបានបំភ្លេចចោល)

[27] **E284/4/1** បណ្តឹងសាទុក្ខភ្លាមៗរបស់ នួន ជា, កំណត់សម្គាល់*ខាងលើ*លេខ២ ត្រង់កថាខណ្ឌ ៣៣។

[28] **E284/4/1** *ដដែលដូចមុន* ត្រង់កថាខណ្ឌ ៤១។

[29] **E124/5** ចម្លើយតបទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាសុំឱ្យពិចារណាឡើងវិញ, កំណត់សម្គាល់*ខាងលើ*លេខ១៧ ត្រង់កថាខណ្ឌ៣។

[30] វិធាន ២១(ឃ)៖ "ជនណាដែលត្រូវបានសង្ស័យ ឬ ត្រូវបានចោទប្រកាន់ ត្រូវចាត់ទុកថាគ្មានទោស ដរាបណាពិរុទ្ធភាពរបស់គេ មិនទាន់ត្រូវបានរកឃើញ"។

[31] **E176/2** សេចក្តីសម្រេចលើសំណើសុំឱ្យចាត់ការជាបន្ទាន់ តាមវិធាន ៣៥, ១១ ឧសភា ២០១២ ត្រង់កថាខណ្ឌ ១៦។

១៣- ជាការសំខាន់ផងដែរ នៅក្នុងការកត់សម្គាល់ថា នៅពេលដែល នួន ជា បានផ្ដល់សក្ខីកម្មនៅពេលចាប់ផ្ដើមកិច្ចដំណើរការនីតិវិធីសវនាការ គាត់បានធ្វើសេចក្ដីថ្លែងទូលំទូលាយមួយដែលមិនកម្រិតទៅលើបញ្ហាជម្លៀសដោយបង្ខំនោះទេ ប៉ុន្តែបែរធ្វើការពន្យល់យ៉ាងក្បោះក្បាយមួយ និងបានការពារចលនា បកក និងរបបកម្ពុជាប្រជាធិបតេយ្យទៅវិញ[32]។ នួន ជា បានលើកឡើងពីបញ្ហានានា តាំងពីគោលជំហររបស់ បកក ស្ដីពីព្រះពុទ្ធសាសនា[33] សេដ្ឋកិច្ច និងគោលនយោបាយសង្គម[34] គោលនយោបាយការបរទេស (រួមមាន ទំនាក់ទំនងជាមួយវៀតណាម និងការគំរាមកំហែងដែលបានមើលឃើញថាមកពីពួកវៀតណាម)[35] រហូតដល់ការអនុវត្តខាងផ្នែកសន្តិសុខទាក់ទងនឹងពួកខ្មាំង[36]។ ទាំងអង្គជំនុំជម្រះសាលាដំបូង និងទាំងភាគីនានា មិនបានស្វែងរកនូវការកម្រិតលើប្រធានបទនានាដែល នួន ជា បានលើកឡើងនៅក្នុងសេចក្ដីថ្លែងផ្សេងៗរបស់គាត់ ក្នុងរយៈពេលកំពុងធ្វើសវនាការនោះទេ។ តាមការពិត គឺមានតែការកម្រិតបែបដូច្នេះប៉ុណ្ណោះ បានដាក់ទៅលើខ្លួនគាត់។ ឧទាហរណ៍ នួន ជា នាពេលថ្មីៗនេះ បានផ្ដល់ប្រឹក្សាដល់អង្គជំនុំជម្រះសាលាដំបូងថា គាត់នឹងផ្ដល់សក្ខីកម្ម និងធ្វើការឆ្លើយតបទៅនឹងសំណួរទាំងឡាយ នៅដំណាក់កាលចុងក្រោយនៃសវនាការលើសំណុំរឿង០០២/០១ ប៉ុន្តែទាក់ទងនឹងប្រធានបទមួយប៉ុណ្ណោះ "រហូតដល់ និងរួមបញ្ចូលទាំងការជម្លៀសប្រជាជនដំណាក់កាលទីI និងអង្គហេតុនានាដែលបានចោទប្រកាន់នៅទួលពោធិ៍ជ្រៃ"[37]។ ដូច្នេះ មេធាវីការពារក្ដីមិនមានមូលដ្ឋានអ្វីទាល់តែសោះក្នុងការអះអាងថា "វិសាលភាពមានកម្រិតនៃសំណុំរឿង០០២/០១ បានបង្កព្យសនកម្មដល់ នួន ជា យ៉ាងខ្លាំង ដោយបានបង្អាក់លទ្ធភាពរបស់គាត់ក្នុងការឡើងការពារខ្លួនឲ្យបានពេញលេញ និងប្រកបដោយប្រសិទ្ធភាព"[38]។

១៤- មេធាវីការពារក្ដីអះអាងបន្ថែមទៀតថា សេចក្ដីសម្រេចដែលរងការជំទាស់នេះ "មិនបានពិចារណាទៅលើសេចក្ដីសន្និដ្ឋាននានារបស់មេធាវីការពារក្ដី"[39]។ មេធាវីការពារក្ដីបានធ្វើការសន្និដ្ឋានថា អង្គជំនុំជម្រះសាលាដំបូងខកខានមិនបានលើកឡើងពីអំណះអំណាងបី៖ (១) តើផលប្រយោជន៍របស់ នួន

---

[32] សូមអាន **E1/14.1** ប្រតិចារឹក, ២២ វិច្ឆិកា ២០១១ ត្រង់ទំព័រទី ៧៦-១១២។

[33] **E1/21.1** ប្រតិចារឹក, ១៣ ធ្នូ ២០១១ ត្រង់ទំព័រទី ៣៩-៤៤។ **E1/23.1** ប្រតិចារឹក, ១៥ ធ្នូ ២០១១ ត្រង់ទំព័រទី ៨០-៨២, ៨៨-៨៩។

[34] **E1/14.1** ប្រតិចារឹក, 22 វិច្ឆិកា ២០១១ ត្រង់ទំព័រទី ១០៨-១១១។ **E1/21.1** ប្រតិចារឹក, ១៣ ធ្នូ ២០១១ ត្រង់ទំព័រទី ២៩-៣៤។

[35] **E1/14.1** ប្រតិចារឹក, 22 វិច្ឆិកា ២០១១ ត្រង់ទំព័រទី ៧៨-៨១, ៩៧-១០៧។ **E1/16.1** ប្រតិចារឹក, ៥ ធ្នូ ២០១១ ត្រង់ទំព័រទី ៥១-៥៣។

[36] **E1/21.1** ប្រតិចារឹក, ១៣ ធ្នូ ២០១១ ត្រង់ទំព័រទី ៦-៩។ **E1/26.1** ប្រតិចារឹក, ១២ មករា ២០១២ ត្រង់ទំព័រទី ៨-៩។

[37] **E287** សេចក្ដីជូនដំណឹងអំពីបំណងដោយអនុលោមតាមវិធាន ៩០, ២៧ ឧសភា ២០១៣ ត្រង់កថាខណ្ឌ ២។

[38] **E284/4/1** បណ្ដឹងសាទុក្ខភ្លាមៗរបស់ នួន ជា, កំណត់សម្គាល់*ខាងលើ* លេខ២ ត្រង់កថាខណ្ឌ ១៣។

[39] **E284/4/1** *ដដែលដូចមុន* ត្រង់កថាខណ្ឌ ៩។

ជា ក្នុងការបង្ហាញការការពារខ្លួន ឬការតទល់លើភ័ស្តុតាងដាក់បន្ទុកប្រឆាំងនឹងខ្លួន ត្រូវបានការពារយ៉ាងដូចម្តេច នៅក្នុងបរិបទនៃការជំនុំជម្រះដែលត្រូវបានបំបែកកិច្ចដំណើរការនីតិវិធីនេះ ឬក៏ថាតើហេតុអ្វីបានជាផលប្រយោជន៍ក្នុងការរៀបចំបំបែកកិច្ចដំណើរការនីតិវិធីនេះ មិនមានតម្លៃជាង (២) តើចាំបាច់ និងអាច ត្រូវបង្កើតក្រុមប្រឹក្សាជំនុំជម្រះទីពីរ ដែរឬទេ ឬថាតើអង្គជំនុំជម្រះសាលាដំបូងអាចការពារបានភាពលម្អៀងដោយរបៀបណា នៅពេលដែលគ្មានក្រុមប្រឹក្សាជំនុំជម្រះទីពីរទេ (៣) ដោយការខកខានមិនបានបង្កើតផែនការជាក់ស្តែងសម្រាប់ការជំនុំជម្រះ ដែលនៅសេសសល់ នាពេលអនាគត[40]។ មានតែទឡ្ហីករណ៍ទីមួយក្នុងចំណោមទឡ្ហីករណ៍ទាំងនេះប៉ុណ្ណោះទេ ដែលគួរឲ្យជឿបានថា មានទំនាក់ទំនងទៅនឹងសិទ្ធិរបស់ជនជាប់ចោទនៅក្នុងសំណុំរឿង០០២/០១។ ទាក់ទងនឹងទឡ្ហីករណ៍ទីពីរ បញ្ហានានាដែលទាក់ទងនឹងភាពលម្អៀងដែលបានចោទប្រកាន់នៃក្រុមប្រឹក្សាជំនុំជម្រះនៅក្នុងសំណុំរឿង០០២/០១ គឺមិនមានពាក់ព័ន្ធនឹងបណ្តឹងសាទុក្ខនេះឡើយ ដែលយុត្តាធិការរបស់វាកើតចេញមកពីសេចក្តីសន្និដ្ឋានដែលថា មិនមានការសង្ឃឹមជាក់ស្តែងដែលថាសវនាការបន្ថែមទៀតបែបដូច្នេះ នឹងកើតឡើងនោះឡើយ។ ទាក់ទងនឹងទឡ្ហីករណ៍ទីបី ដូចដែលមេធាវីការពារក្តីបានកត់សម្គាល់ដូច្នោះដែរ សហព្រះរាជអាជ្ញាក៏បានសង្កេតឃើញផងដែរនូវការខកខានរបស់អង្គជំនុំជម្រះសាលាដំបូង ដែលមិនបានបង្កើតផែនការជាក់ស្តែងសម្រាប់ការជំនុំជម្រះដែលនៅសេសសល់នាពេលអនាគត[41]។ យ៉ាងណាក៏ដោយ នេះគឺជាការខកខានមួយដែលត្រូវគ្នាទៅនឹងសេចក្តីណែនាំរបស់អង្គជំនុំជម្រះនេះ គឺពុំមែនជាការខកខានមិនបានធ្វើការពិចារណាលើអំណះអំណាងរបស់មេធាវីការពារក្តីនោះឡើយ ដែលគ្រាន់តែជាអំណះអំណាងដែលបានថាតាមដូចសេក យឺតពេល ដែលសហព្រះរាជអាជ្ញា និងដើមបណ្តឹងរដ្ឋប្បវេណីបានលើកឡើងពីមុនរួចហើយ[42]។

១៥- ទាក់ទងទៅនឹងការពិចារណារបស់អង្គជំនុំជម្រះសាលាដំបូង លើអំណះអំណាងរបស់មេធាវីការពារក្តីស្តីពីការបំបែកកិច្ចដំណើរការនីតិវិធី សហព្រះរាជអាជ្ញារំលឹកថា អង្គជំនុំជម្រះនេះធ្លាប់បានសម្រេចពីមុនថា "អង្គជំនុំជម្រះសាលាដំបូងមិនតម្រូវឲ្យបញ្ជាក់រាល់សម្អាងហេតុលើការយល់ឃើញនីមួយៗរបស់ខ្លួននោះឡើយ"[43]។ លើសពីនេះ អង្គជំនុំជម្រះសាលាដំបូងបានកត់សម្គាល់យ៉ាងច្បាស់ ថា

---

[40] **E284/4/1** *ដដែលដូចមុន* ត្រង់កថាខណ្ឌ ២៣-២៤។

[41] **E284/2/1** សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញា, កំណត់សម្គាល់*ខាងលើ* លេខ៥ ត្រង់កថាខណ្ឌ ៧៨។

[42] សូមអាន **E163/5/1/13** សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញា ស្តីពីវិសាលភាព, កំណត់សម្គាល់*ខាងលើ* លេខ៧ ត្រង់កថាខណ្ឌ ៤៧ (ដោយបានកត់សម្គាល់ថា អំណះអំណាងទាំងនេះត្រូវបានលើកឡើងដោយសហព្រះរាជអាជ្ញា និង ដើមបណ្តឹងរដ្ឋប្បវេណី)។

[43] **E163/5/1/13** *ដដែលដូចមុន* ត្រង់កថាខណ្ឌ ៣៦។

អំណះអំណាងរបស់មេធាវីការពារក្តីថា “ចម្លើយតបតែមួយដែលអាចធ្វើទៅបានចំពោះការមោឃភាពទៅលើដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី ព្រមទាំងអាចជួសជុលចំពោះភាពមិនប្រាកដប្រជាដែលបណ្តាលមកពីការបំបែកកិច្ចដំណើរការនីតិវិធីនេះ គឺការបន្តកិច្ចដំណើរការនីតិវិធី ដោយធ្វើសវនាការផ្អែកលើដីកាដំណោះស្រាយទាំងមូលនៃសំណុំរឿងលេខ០០២”[44]។ អង្គជំនុំជម្រះសាលាដំបូងបានពិចារណា ដោយមកពី “ការកម្រិតក្នុងការបំបែកកិច្ចដំណើរការនីតិវិធីចាំបាច់ កាលពីក្នុងខែកញ្ញា ឆ្នាំ២០១១ (គឺដោយសារតែមូលហេតុវ័យចាស់ជរា និងការបន្តចុះខ្សោយផ្នែករាងកាយរបស់ជនជាប់ចោទទាំងអស់ក្នុងសំណុំរឿង០០២។ ភាពមិនអាចទៅរួចដែលថា ការចោទទាំងអស់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ក្នុងសំណុំរឿង០០២ អាចត្រូវបានធ្វើសវនាការក្នុងអំឡុងពេលពួកគាត់នៅមានជីវិត ឬនៅមានកាយសម្បទា និងបញ្ញាស្មារតីគ្រប់គ្រាន់ក្នុងការចូលរួមសវនាការនេះបាន”[45] “ការបំបែកកិច្ចដំណើរការនីតិវិធីនៃដីកាដំណោះស្រាយក្នុងសំណុំរឿង០០២ នៅតែជាលក្ខខណ្ឌតម្រូវដើម្បីផលប្រយោជន៍នៃយុត្តិធម៌”[46]។ នៅក្នុងរឿងនេះ អង្គជំនុំជម្រះសាលាដំបូងបានធ្វើសេចក្តីយោងយ៉ាងជាក់ច្បាស់លើ “ការជំទាស់ថ្មីៗពីសំណាក់មេធាវីការពារក្តី អំពីទស្សនៈនៃការបំបែកកិច្ចដំណើរការនីតិវិធី”[47]។ ដូច្នេះ នៅក្នុងរឿងនេះ អង្គជំនុំជម្រះសាលាដំបូងបានទទួលយកអំណះអំណាងរបស់មេធាវីការពារក្តីមកធ្វើការពិចារណា។

១៦- ការចោទប្រកាន់បន្ថែមទៀតនៅក្នុងបណ្តឹងសាទុក្ខ គឺដូចតែគ្នា មិនគួរឲ្យជឿតាមបានទេ។ អំណះអំណាងដែលថា “មានការលំបាក និងចំណាយពេលច្រើននៅក្នុងការបំបែកផ្នែកដែលពាក់ព័ន្ធនឹងសក្ខីកម្មរបស់សាក្សីម្នាក់ៗឲ្យរួសពីវិសាលភាព ដែលនាំឲ្យមានការជំទាស់ជារឿយៗពីភាគីនានា និងមានការប្រជុំពិភាក្សាសម្រេចជាញឹកញាប់ពីអង្គជំនុំជម្រះ”[48] ពិបាកបង្ហាញពីការរំលោភសិទ្ធិរបស់ជនជាប់ចោទ។ ទីមួយ ការអះអាងនេះ គឺបង្ហាញថាមិនត្រឹមត្រូវ ពីព្រោះសវនាការបានដំណើរការដោយជោគជ័យ តាមរយៈការសួរដេញដោលសាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីចំនួនជាង ៨០ នាក់មកដល់បច្ចុប្បន្ននេះ។ បន្ថែមលើនេះ អង្គហេតុដែលភាគីនានា រួមទាំងមេធាវីការពារក្តីផងនោះ បានធ្វើការជំទាស់នៅក្នុងអំឡុងពេលធ្វើការសួរដេញដោល ហើយអង្គជំនុំជម្រះសាលាដំបូង បាន

[44] **E284** សេចក្តីសម្រេចលើសំណុំរឿង ០០២ បន្ទាប់ពីមានសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី ០៨ ខែកុម្ភៈ ឆ្នាំ២០១៣, ២៦ មេសា ២០១៣ ត្រង់កថាខណ្ឌ ៥២។ សូមអានផងដែរ *ដដែលដូចមុន* ត្រង់កថាខណ្ឌ ៥៩-៦០, ៦៧, ៧៨, ៨២។

[45] **E284** *ដដែលដូចមុន* ត្រង់កថាខណ្ឌ ៨៧។

[46] **E284** *ដដែលដូចមុន* ត្រង់កថាខណ្ឌ ៩០។

[47] **E284** *ដដែលដូចមុន* ត្រង់កថាខណ្ឌ ៨៨។

[48] **E284/4/1** បណ្តឹងសាទុក្ខភ្លាមៗរបស់ នួន ជា, កំណត់សម្គាល់*ខាងលើ* លេខ២ ត្រង់កថាខណ្ឌ ២០។

ពិចារណាលើការជំទាស់ទាំងនោះតាមរយៈពិភាក្សាដេញដោលនានា គឺមិនគ្រាន់តែជាវិធីមួយ ដែលសវនាការអាចដំណើរការទៅមុខជាក់ស្តែងប៉ុណ្ណោះទេ ថែមទាំងផ្តល់នូវភស្តុតាងរឹងមាំទៀតផង ដែលសិទ្ធិតាមកិច្ចដំណើរការនីតិវិធីរបស់ជនជាប់ចោទត្រូវបានគោរព មិនមែនត្រូវបានរំលោភទេ។ លើសពីនេះ ការអះអាងបែបដូច្នេះគឺមិនអាចជឿជាក់បានទេនៅពេលនេះ ដែលថាសាក្សីមួយភាគធំនឹងត្រូវកោះហៅនៅក្នុងសំណុំរឿង០០២/០១ ត្រូវបានសួរដេញដោលបានដោយជោគជ័យ[49]។

### *គ. ការបន្ថែមបទចោទដែលបានលេចចេញពីឧក្រិដ្ឋកម្មនៅស-២១ សមស្របទៅនឹងលក្ខខណ្ឌតម្រូវស្តីពីភាពតំណាងសមហេតុសមផលនៃបទចោទនៅក្នុងដីកាដំណោះស្រាយ និងស្ថិតនៅក្នុងផលប្រយោជន៍នៃយុត្តិធម៌*

១៧- ដូចដែលយុត្តិសាស្ត្ររបស់អង្គជំនុំជម្រះនេះបានបង្កើតឡើង វិធាននានាស្តីពីនីតិវិធីអន្តរជាតិ បានចែងអំពីការបំបែកកិច្ចដំណើរការនីតិវិធី ដើម្បីផលប្រយោជន៍នៃយុត្តិធម៌ វិសាលភាពនៃសវនាការដែលបានបំបែក គួរមាន*ភាពជាតំណាងសមហេតុផល*នៃបទចោទទាំងមូល[50]។ សហព្រះរាជអាជ្ញាយល់ស្របជាមួយមេធាវីការពារក្តីថា អង្គជំនុំជម្រះសាលាដំបូង "ខកខានយ៉ាងច្បាស់មិនបានបំពេញកិច្ចខិតខំប្រឹងប្រែងស្របច្បាប់ណាមួយ ដើម្បីរៀបចំឲ្យមានតំណាងសមហេតុផលមួយក្នុងការជំនុំជម្រះនៅក្នុងសំណុំរឿង០០២/០១" ហើយថា "វិសាលភាពទូលំទូលាយ" នៃសំណុំរឿង០០២/០១ គឺ "អាចធ្វើបាន និងមានលក្ខណៈចាំបាច់"[51]។ យ៉ាងណាក៏ដោយ សហព្រះរាជអាជ្ញាមិនយល់ស្របជាមួយនឹងមេធាវីការពារក្តីទេ ថា អង្គជំនុំជម្រះសាលាដំបូងមានកាតព្វកិច្ចត្រូវធ្វើសវនាការលើដីកាបញ្ជូនរឿងទៅជំនុំជម្រះទាំងមូលនៃសំណុំរឿង០០២។ អង្គជំនុំជម្រះនេះធ្លាប់បានទទួលស្គាល់ថា អង្គជំនុំជម្រះសាលាដំបូងអាចរើសយកនូវ "ការជំនុំជម្រះមួយផ្នែកតូចនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ" ដោយពិចារណាទៅលើអាយុ និងសុខភាពរបស់ជនជាប់ចោទ ប្រសិនបើការណ៍នេះផ្តល់នូវ "ការ

[49] សូមអាន **E288** អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពី៖ ការជូនដំណឹងអំពីសវនាការដែលនៅសេសសល់មុនពេលបិទកិច្ចដំណើរការនីតិវិធីសវនាការលើភស្តុតាងនៅក្នុងសំណុំរឿង ០០២/០១ និងការកំណត់កាលបរិច្ឆេទនៃកិច្ចប្រជុំរៀបចំសវនាការលើកចុងក្រោយ សម្រាប់ថ្ងៃទី ១៣ ខែមិថុនា ឆ្នាំ២០១៣, ៣១ ឧសភា ២០១៣។

[50] **E163/5/1/13** សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញា ស្តីពីវិសាលភាព, កំណត់សម្គាល់*ខាងលើ* លេខ៧ ត្រង់កថាខណ្ឌ ៤២។

[51] **E284/4/1** បណ្តឹងសាទុក្ខភ្លាមៗរបស់ នួន ជា, កំណត់សម្គាល់*ខាងលើ* លេខ២ ត្រង់កថាខណ្ឌ ២៩.៣១.៣៥។

ពិចារណាសមស្របទៅលើភាពតំណាងសមហេតុផលនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ នៅក្នុងការជំនុំជម្រះតូចៗជាងនេះ”[52]។

១៨- នៅក្នុងការកំណត់ថាតើគេត្រូវធ្វើការចោទប្រកាន់លើបទចោទមួយណា នៅក្នុងសវនាការដែលមានលក្ខណៈតូចជាង និងជាសវនាការតែមួយ នោះសហព្រះរាជអាជ្ញាសន្និដ្ឋានថា គេត្រូវផ្តល់ជូននូវឆន្ទានុសិទ្ធិ និងការវិនិច្ឆ័យរបស់ពួកគាត់ ទាក់ទងនឹងបទចោទសមស្របដែលគេត្រូវធ្វើការជំនុំជម្រះលើជនជាប់ចោទ។ អង្គជំនុំជម្រះនេះធ្លាប់បានទទួលស្គាល់ “តួនាទី និងការទទួលខុសត្រូវសំខាន់របស់សហព្រះរាជអាជ្ញានៅក្នុងការធ្វើដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ និងការបង្ហាញបទចោទនៅក្នុងដីកានោះផងដែរ”[53]។ សេចក្តីសន្និដ្ឋានពីមុនៗរបស់សហព្រះរាជអាជ្ញាក៏ធ្លាប់បានលើកឡើងផងដែរអំពីតួនាទីក្នុងការចោទប្រកាន់ផ្សេងពីគ្នា នៅក្នុងការបង្កើតឲ្យមានដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលបានបំបែកកិច្ចដំណើរការនីតិវិធីរួចហើយនេះ ឲ្យលេចចេញជារូបរាងឡើង នៅតាមតុលាការ*ពិសេស*នានា[54]។

១៩- នៅក្នុងមតិរបស់សហព្រះរាជអាជ្ញាដែលថា បទចោទធ្ងន់ធ្ងរបំផុតដែលមាននៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះលើសំណុំរឿង០០២ កើតចេញពីការចោទប្រកាន់ដែលថា ជនជាប់ចោទបានត្រួតត្រាលើបណ្តាញប្រព័ន្ធសន្តិសុខមួយនៅទូទាំងកម្ពុជាប្រជាធិបតេយ្យ ដែលក្នុងនោះមានប្រជាជនកម្ពុជារាប់ម៉ឺននាក់ ត្រូវបានឃុំខ្លួន ត្រូវបានទទួលទារុណកម្ម និងត្រូវបានប្រហារជីវិតដោយខុសច្បាប់។ ដីកាបញ្ជូនរឿងទៅជំនុំជម្រះបានចោទប្រកាន់ទៅលើជនជាប់ចោទពីឧក្រិដ្ឋកម្មនានា ដោយរួមជាមួយនឹងមន្ទីរសន្តិសុខ និងទីកន្លែងសម្លាប់មនុស្សដែលពាក់ព័ន្ធបែបដូច្នេះចំនួន១១កន្លែង ដែលមន្ទីរសន្តិសុខនិងទីកន្លែងសម្លាប់មនុស្សបែបដូច្នេះ មិនត្រូវបានគេដាក់បញ្ចូលទៅក្នុងវិសាលភាពនៃសំណុំរឿង០០២/០១ ឡើយ។

២០- ជាសរុប មេធាវីការពារក្តីបានចោទប្រកាន់ថា ស-២១ មិនមែនជា “តំណាងតែមួយគត់” នៃដីកាដំណោះស្រាយឡើយ ដោយឈរលើមូលដ្ឋាននៃជនរងគ្រោះដែលបានចោទប្រកាន់ វិសាលភាពភូមិសាស្ត្រ និងពេលវេលា ឧក្រិដ្ឋកម្មនានាដែលបានចោទប្រកាន់ និង ខ្លឹមសារជាមូលដ្ឋាននៃរឿងក្តីនេះ

---

[52] **E163/5/1/13** សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញា ស្តីពីវិសាលភាព, កំណត់សម្គាល់*ខាងលើ* លេខ៧ ត្រង់កថាខណ្ឌ ៥០។

[53] **E163/5/1/13** *ដដែលដូចមុន* ត្រង់កថាខណ្ឌ ៤២។

[54] **E124/2** សំណើសុំឲ្យពិចារណាឡើងវិញ, កំណត់សម្គាល់*ខាងលើ* លេខ១៦ ត្រង់កថាខណ្ឌ ២០។

ហើយមិនបានដាក់បញ្ចូលត្រឹមត្រូវដោយអង្គជំនុំជម្រះសាលាដំបូង[55]។ ដោយហេតុថាស-២១តំណាងឲ្យមន្ទីរសន្តិសុខច្រើនស្ថិតនៅក្នុងអង្គហេតុដែលបានចោទប្រកាន់ទាំងមូលនៅក្នុងសំណុំរឿងនេះ សហព្រះរាជអាជ្ញាជំទាស់ទៅនឹងគោលជំហរនេះ ជាពិសេស អង្គហេតុដែលបានចោទប្រកាន់ដាក់បន្ទុកដោយផ្ទាល់ចំពោះសហជនជាប់ចោទ។

២១- ស-២១ គឺជាមន្ទីរសន្តិសុខមួយ និងតែមួយគត់ ហើយជាទីតាំងឧក្រិដ្ឋកម្មតែមួយគត់ នៅក្នុងដីកាដំណោះស្រាយ ដែលមានជនជាប់ចោទ នួន ជា "ជាអ្នកមើលការខុសត្រូវដោយផ្ទាល់"[56]។ សហចៅក្រមស៊ើបអង្កេតបានរកឃើញថា ជនជាប់ចោទ នួន ជា "បានសន្មតនូវការទទួលខុសត្រូវសំខាន់ៗសម្រាប់ការអនុវត្តគោលនយោបាយ" តាមរយៈ "ការគ្រប់គ្រង ស-២១ និងសន្តិសុខផ្ទៃក្នុងនៅទូទាំងកម្ពុជា"[57]។ សហចៅក្រមស៊ើបអង្កេតបានរកឃើញថា "យ៉ាងហោចណាស់" ចម្លើយសារភាពចំនួន "២៧" មានចំណារបញ្ជាក់ថា មួយច្បាប់ត្រូវបានផ្ញើទៅឲ្យ នួន ជា ហើយចម្លើយសារភាព ស-២១ ចំនួនប្រាំមួយផ្សេងទៀត មានចំណារសរសេរដោយដៃ នួន ជា"[58]។ នួន ជា ត្រូវបានចោទថា ជាអ្នកដែលមានការទទួលខុសត្រូវដោយផ្ទាល់ក្នុងការធ្វើសេចក្ដីសម្រេច ដើម្បីចាប់ខ្លួនបុគ្គលនានាដែលបានបញ្ជូនមកស-២១ និងជាអ្នកដែលបានបញ្ជាដោយផ្ទាល់ក្នុងការសម្លាប់អ្នកទោសស-២១[59]។ ហេតុដូច្នេះហើយ គេមិនមានការភ្ញាក់ផ្អើលទេ ដែលមេធាវីការពារក្ដីមិនចង់ឲ្យស-២១ ដាក់បញ្ចូលក្នុងវិសាលភាពនៃសំណុំរឿង០០២/០១ ហើយនៅក្នុងតួរយ៉ាងមួយនេះ គេជឿថា សេចក្ដីសម្រេចដែលរងការជំទាស់នេះគួរតែទទួលបាននូវការពន្យារ[60]។ មេធាវីការពារក្ដីមិនជំទាស់នឹងទំនាក់ទំនងជិតស្និទ្ធនិងដោយផ្ទាល់រវាងជនជាប់ចោទ និងស-២១ទេ ហើយខកខានមិនបានផ្ដល់មូលហេតុណាមួយនាំឲ្យជឿបានថា ហេតុអ្វីបានជាមិនមែនកត្តាសំខាន់នៅក្នុងការសម្រេចអំពីវិសាលភាពនៃសំណុំរឿង ០០២/០១[61]។

---

[55] **E284/4/1** បណ្ដឹងសាទុក្ខភ្លាមៗរបស់ នួន ជា, កំណត់សម្គាល់*ខាងលើ* លេខ២ ត្រង់កថាខណ្ឌ ៥៧-៧១។

[56] **D427** ដីកាដំណោះស្រាយ, ១៥ កញ្ញា ២០១០, ត្រង់កថាខណ្ឌទី៤២១, ៩៥២, ៩៥៩។

[57] **D427** *ក្នុងឯកសារដដែលដូចខាងលើ,* ត្រង់កថាខណ្ឌទី១៥៥២។

[58] **D427** *ក្នុងឯកសារដដែលដូចខាងលើ,* ត្រង់កថាខណ្ឌទី៩៦៤ (កំណត់សម្គាល់ជើងទំព័រ៤០២៩ និង ៤០៣១), ៩៦៦។

[59] **D427** *ក្នុងឯកសារដដែលដូចខាងលើ,* ត្រង់កថាខណ្ឌទី៤៦៧, ៩៥៨-៩៦២, ៩៧០, ៩៧២-៩៧៣។

[60] **E284/4/1** បណ្ដឹងសាទុក្ខភ្លាមៗរបស់ នួន ជា, កំណត់សម្គាល់*ខាងដើម* លេខ២ ត្រង់កថាខណ្ឌទី៥៦។

[61] E284/4/1 *ក្នុងឯកសារដដែលដូចខាងលើ,* ត្រង់កថាខណ្ឌទី ៦៩-៧១។

២២- អំណះអំណាងជាក់លាក់ដែលបានធ្វើឡើងដោយមេធាវីការពារក្តីទាក់ទងនឹងភាពជាតំណាងនៃ ស-២១ មិនអាចទប់ទល់នឹងការពិនិត្យពិច័យបានឡើយ។ មេធាវីការពារក្តីមានកំហុសទីមួយ តាមរយៈការកំហិតការវិភាគរបស់ខ្លួនចំពោះថាតើ ស-២១ អាចជាតំណាងនៃទីតាំងឧក្រិដ្ឋកម្មតែមួយបានដែរ ឬទេ ពីព្រោះផ្តុយទៅនឹងការពិចារណាពាក់ព័ន្ធថាតើ ការបញ្ចូល ស-២១ គឺជារឿងចាំបាច់ដើម្បីធ្វើឲ្យសំណុំរឿង០០២/០១ ជាតំណាងឲ្យដីកាបញ្ជូនរឿងទៅជំនុំជម្រះទាំងមូលដែរ ឬទេ។ មេធាវីការពារក្តីមិនអាចអះអាងឲ្យជឿបានទេថា មន្ទីរសន្តិសុខមួយក្នុងចំណោមមន្ទីរសន្តិសុខទាំងដប់មួយដែលបង្កើតបានជាមូលដ្ឋាននៃអង្គហេតុសម្រាប់បទចោទនានាប្រឆាំងនឹង នួន ជា មិនមែនជាធាតុផ្សំសំខាន់នៃការបំបែកកិច្ចដំណើរការនីតិវិធីណាមួយ ដែលតំណាងសមហេតុផលនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះនោះទេ។ មេធាវីការពារក្តីមិនបានផ្តល់មូលហេតុធម្មានុរូប ហេតុអ្វីបានជាមន្ទីរសន្តិសុខមួយនោះ មិនគួរជា ស-២១ ដែលជាមន្ទីរសន្តិសុខកម្រិតខ្ពស់បំផុតនៅក្នុងប្រទេស ជាមន្ទីរសន្តិសុខតែមួយគត់ដែលបានដាក់អ្នកទោសពីគ្រប់ផ្នែកទាំងអស់របស់ប្រទេស និងជាមន្ទីរសន្តិសុខតែមួយគត់ដែលបានរាយការណ៍ជូនជនជាប់ចោទដោយផ្ទាល់។

២៣- អំណះអំណាងរបស់មេធាវីការពារក្តីដែលថា អង្គជំនុំជម្រះសាលាដំបូងមិនដាក់បញ្ចូល ស-២១ ដើម្បីផ្តល់បុព្វសិទ្ធិចំពោះ "ការវិនិច្ឆ័យលើការទាមទារបដិទាន និងការចោទប្រកាន់អង្គហេតុដែលមិនទាន់បានដោះស្រាយ"[62] គឺជាការមិនអើពើចំពោះភាពខុសគ្នាជាមូលដ្ឋានរវាងសំណុំរឿង០០១ និង០០២។ ដោយកើតចេញពីមូលដ្ឋានឧក្រិដ្ឋកម្មដូចគ្នា បទចោទនានាដែលជាប់ទាក់ទងនឹងស-២១ ក្នុងសំណុំរឿង ០០១ ជាប់ពាក់ព័ន្ធនឹងការដំណើរការផ្ទៃក្នុង នៃទីតាំងឃុំឃាំង ធ្វើទារុណកម្ម និងសម្លាប់មនុស្ស និងការទទួលខុសត្រូវរបស់ប្រធានមន្ទីរនេះ។ បទចោទជាប់ទាក់ទងនឹងស-២១ ដែលសហព្រះរាជអាជ្ញាស្វែងរក ដើម្បីដាក់បញ្ចូលទៅក្នុងសំណុំរឿង០០២ គឺមានការពាក់ព័ន្ធនឹងតួនាទីរបស់មន្ទីរនេះក្នុងនាមជាឧបករណ៍មួយដែលបានបង្កើតឡើង និងដែលបានគ្រប់គ្រងដោយមេដឹកនាំជាន់ខ្ពស់របស់កម្ពុជាប្រជាធិបតេយ្យ ក្នុងការអនុវត្តគោលនយោបាយរបស់ពួកគេ ដែលអ្នកប្រឆាំងខាងផ្នែកនយោបាយ និងជនដែលគេយល់ថាខ្មាំងទាំងអស់នៃរបបនេះ អាចត្រូវបានកម្ទេចចោល។ ការប្រៀបធៀបសំណុំរឿងទាំងពីរថាដូចគ្នា ដូចដែលមេធាវីការពារក្តីព្យាយាមធ្វើនេះ គឺជាការភាន់ច្រឡំប្រភេទ ដូចជាតួនាទីតាមឋានានុក្រមពាក់ព័ន្ធ និងកម្រិតនៃការទទួលខុសត្រូវ។

---

[62] E284/4/1 *ក្នុងឯកសារដដែលដូចខាងលើ,* ត្រង់កថាខណ្ឌទី៧២។

២៤- អំណះអំណាងរបស់មេធាវីការពារក្តីដែលថា ការវិនិច្ឆ័យដ៏ត្រឹមត្រូវចំពោះស-២១ តម្រូវឱ្យមានសក្ខីកម្មផ្ទាល់មាត់ "ដើម្បីកំណត់ថាអ្នកជាប់ឃុំនៅស-២១ គឺជាគោលដៅយោធាស្របច្បាប់"[63] គឺជារឿងគួរឱ្យស្អប់ខ្ពើមខាងសីលធម៌ និងគ្មានមូលដ្ឋានខាងផ្លូវច្បាប់។ ទីមួយ ព្រឹត្តិការណ៍នានានៅស-២១ បានកើតឡើងជិត២០ឆ្នាំ បន្ទាប់ពីកម្ពុជាបានក្លាយជារដ្ឋភាគីនៃអនុសញ្ញាទីក្រុងហ្សឺណែវ ឆ្នាំ១៩៥៩[64] និងនៅពេលដែលគោលការណ៍ច្បាប់មានចែងនៅក្នុងអនុសញ្ញានេះ គឺជាផ្នែកមួយនៃច្បាប់ទំនៀមទំលាប់អន្តរជាតិដែលចងកាតព្វកិច្ច។ ដូចនេះ សូម្បីតែជនរងគ្រោះនៅស-២១ ភាគច្រើន ត្រូវបានកំណត់គោលដៅដោយសហជនជាប់ចោទ នួន ជា និង ខៀវ សំផន សម្រាប់គោលបំណង "យោធា" ការឃុំឃាំង ការធ្វើទារុណកម្ម និងការសម្លាប់ បង្កើតបានជាការរំលោភធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ និងការរំលោភលើមាត្រា៣ជារួមនៃអនុសញ្ញានេះ។ ទីពីរ ជនរងគ្រោះនៅស-២១ភាគច្រើនមិនមែនជាអ្នកទោសជាយោធាដែលពាក់ព័ន្ធនឹងកម្លាំងយោធាបដិបក្ខទេ ប៉ុន្តែជាជនស៊ីវិលធម្មតា ជាកម្មាភិបាល អ្នកធ្វើការក្នុងជួររដ្ឋាភិបាល និងជាសមាជិកនៃកងកម្លាំងប្រដាប់អាវុធរបស់ បកក ដោយផ្ទាល់។ ការកំណត់បទចោទត្រឹមត្រូវតាមផ្លូវច្បាប់ចំពោះឧក្រិដ្ឋកម្មដ៏សាហាវយង់ឃ្នង ដែលបានប្រព្រឹត្តឡើងចំពោះជនរងគ្រោះទាំងនោះ គឺជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ហើយក៏ជាផ្នែកមួយនៃច្បាប់ទំនៀមទំលាប់អន្តរជាតិផងដែរនៅក្នុងឆ្នាំ១៩៧៥ ហើយក៏ដូចជាអនុសញ្ញាទីក្រុងហ្សឺណែវដែលទទួលស្គាល់ "គោលដៅយោធាផ្លូវច្បាប់" ដែលគ្មានអ្វីការពារចំពោះអំពើឧក្រិដ្ឋទាំងឡាយដែលបានប្រព្រឹត្តនៅស-២១។

២៥- ការពិភាក្សារបស់មេធាវីការពារក្តីពីកត្តាផ្សេងៗដែលនឹងត្រូវពិចារណា នៅក្នុងការវាយតម្លៃពីភាពជាតំណាងដូចគ្នានេះ ក៏មិនគាំទ្រចំពោះគោលជំហររបស់ខ្លួន ដែលថា ស-២១ គួរច្រានចោលនោះដែរ៖

ក. *ជនរងគ្រោះដែលបានអះអាង*[65]។ មេធាវីការពារក្តីមិនអាច និងក៏មិនជំទាស់ថា អ្នកទោសនៅស-២១ រួមមាន ពលរដ្ឋកម្ពុជាគ្រប់វ័យ គ្រប់ភេទ គ្រប់ជាតិសាសន៍ និងគ្រប់ជាតិពន្ធុទាំងអស់[66]។ ស-២១ ក៏ជាមន្ទីរសន្តិសុខចំបងដែលជនបរទេសដែលត្រូវបានចាប់ខ្លួនដោយ

[63] E284/4/1 *ក្នុងឯកសារដដែលដូចខាងលើ,* ត្រង់កថាខណ្ឌទី៧៥ ដែលត្រូវអានជាមួយនឹងកថាខណ្ឌទី៨២-៨៣។

[64] សូមមើល ICRC រដ្ឋភាគីទៅនឹងច្បាប់មនុស្សធម៌អន្តរជាតិ និងសន្ធិសញ្ញាពាក់ព័ន្ធដទៃទៀត ចាប់ពីថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៣ ត្រង់ទំព័រទី២៖ កម្ពុជាបានក្លាយជាភាគីនៃអនុសញ្ញាទី៤ ថ្ងៃទី៨ ខែធ្នូ ឆ្នាំ១៩៥៨។

[65] E284/4/1 *ក្នុងឯកសារដដែលដូចខាងលើ,* ត្រង់កថាខណ្ឌទី៥៨។

[66] **E284/2/1** សេចក្តីសម្រេចលើបណ្តឹងសាទុក្ខលើកទីពីររបស់សហព្រះរាជអាជ្ញា, កំណត់សម្គាល់*ខាងដើម* លេខ៥ ត្រង់កថាខណ្ឌទី៣៨។

កងកម្លាំង បកក ត្រូវបានដាក់នៅទីនោះ[67]។ ការពិតដែលថា ភាគច្រើននៃអ្នកទោស គឺជាកម្មាភិបាល កម្មករ និងកងទ័ព បកក មិនមែនបានកែប្រែនូវភាពចម្រុះជាសារវន្តនៃមូលដ្ឋានអ្នកទោសឡើយ។

ខ. *វិសាលភាពប្រជាសាស្ត្រ*[68]។ ស-២១ គឺជាមន្ទីរសន្តិសុខតែមួយគត់ដែលអ្នកទោសនៃគុកនេះ មកពីគ្រប់តំបន់/ភូមិភាគទាំងអស់នៃប្រទេស[69]។ ការអះអាងរបស់មេធាវីការពារក្តីដែលថា ឧក្រិដ្ឋកម្មនានាត្រូវបានគេប្រព្រឹត្តិឡើងតែក្នុងគុកជាក់ស្តែងនេះ នៅទីក្រុងភ្នំពេញនោះ គឺជាការមិនត្រឹមត្រូវ ដោយហេតុថា ឧក្រិដ្ឋកម្មនានាជាញឹកញាប់បានចាប់ផ្តើមតាមរយៈការចាប់ខ្លួនដោយខុសច្បាប់នៃបុគ្គលទាំងនេះ នៅទីកន្លែងដើមរបស់ពួកគេ[70]។ គឺជនជាប់ចោទ នួន ជា និងមេដឹកនាំបក្សដទៃទៀតដែលត្រូវបានចោទថា បានបញ្ជាឲ្យមានការចាប់ខ្លួនអ្នកទោសទាំងនេះនៅតាមបណ្តាទីតាំងផ្សេងៗនៅទូទាំងប្រទេស និងជាអ្នកដែលបានបញ្ជាឲ្យបញ្ជូនអ្នកទាំងអស់នេះមកភ្នំពេញ[71]។ មេធាវីការពារក្តីមិនអាចជំទាស់ថា ស-២១ គឺជាមន្ទីរសន្តិសុខមួយ និងតែមួយគត់ដែលមានវិសាលភាពនៅទូទាំងប្រទេស។

គ. *វិសាលភាពពេលវេលា*[72]។ មេធាវីការពារក្តីមិនអាច និងក៏មិនជំទាស់ថា ការបន្ថែម ស-២១ នឹងបានជាដំណោះស្រាយចំពោះវិសាលភាពពេលវេលាដែលមានកម្រិតនាពេលបច្ចុប្បន្ននៃសំណុំរឿង០០២/០១ និងពង្រីកវិសាលភាពនោះឲ្យបញ្ចូលសម័យកាលទាំងមូលនៃរបបកម្ពុជាប្រជាធិបតេយ្យដែរ[73]។

---

[67] **D427** ដីកាដំណោះស្រាយ, កំណត់សម្គាល់*ខាងដើម* លេខ៧៤ ត្រង់កថាខណ្ឌទី៤៣៣។

[68] **E284/4/1** បណ្តឹងសាទុក្ខភ្លាមៗរបស់ នួន ជា, កំណត់សម្គាល់*ខាងដើម* លេខ២ ត្រង់កថាខណ្ឌទី៥៩។

[69] **D427** ដីកាដំណោះស្រាយ, កំណត់សម្គាល់*ខាងដើម* លេខ៧៤ ត្រង់កថាខណ្ឌទី៤៣១។

[70] **D427** *ក្នុងឯកសារដដែលដូចខាងលើ,* ត្រង់កថាខណ្ឌទី៤៣៤, ៤៣៧-៤៣៨។

[71] **D427** *ក្នុងឯកសារដដែលដូចខាងលើ,* ត្រង់កថាខណ្ឌទី៤៣៤, ៩៦០-៩៦១។

[72] **E284/4/1** បណ្តឹងសាទុក្ខភ្លាមៗរបស់ នួន ជា, កំណត់សម្គាល់*ខាងដើម* លេខ២ ត្រង់កថាខណ្ឌទី៦០។

[73] **E284/2/1** សេចក្តីសម្រេចលើបណ្តឹងសាទុក្ខលើកទីពីររបស់សហព្រះរាជអាជ្ញា, កំណត់សម្គាល់*ខាងដើម* លេខ៥ ត្រង់កថាខណ្ឌទី៤៤។

ឃ. *ឧក្រិដ្ឋកម្មដែលបានចោទប្រកាន់*[74]។ មេធាវីការពារក្ដីមិនជំទាស់ថា ការបញ្ចូល ស-២១ នឹងបន្ថែមទៅលើបទចោទនៃសំណុំរឿង ០០២/០១ នៃអំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរ ព្រមទាំងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដូចបានរៀបរាប់ នៃការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម ការធ្វើឲ្យទៅជាទាសករ ការធ្វើទុក្ខបុកម្នេញដោយមូលហេតុពូជសាសន៍ និងអំពើរំលោភសេពសន្ថវៈ[75] នោះទេ។

ង. *កម្មវត្ថុជាមូលដ្ឋាន ឬលក្ខណៈនៃរឿងក្ដី*។ មេធាវីការពារក្ដីអះអាងថា "ស-២១ មិនមានអ្វីទាំងអស់ពាក់ព័ន្ធនឹងកម្មវត្ថុចំបងនៃរឿងក្ដីនេះ, កិច្ចខិតខំប្រឹងប្រែងរបស់ខ្មែរក្រហមគឺដើម្បីអនុវត្តបដិវត្តន៍សង្គមនិយម តាមរយៈមហាលោតផ្លោះមហាអស្ចារ្យ" និងបានរិះគន់សហព្រះរាជអាជ្ញាថា មិនបាននិយាយពាក្យ "សង្គមនិយម បដិវត្តន៍ [ឬ] កុម្មុយនីស្ដ" នៅក្នុងសេចក្ដីរៀបរាប់របស់ខ្លួន អំពីឧក្រិដ្ឋកម្មស្នូលនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះទេ[76]។ សហព្រះរាជអាជ្ញាសន្និដ្ឋានថា នេះមិនមែនជាការជំនុំជម្រះក្ដីនយោបាយដែលជនជាប់ចោទត្រូវបានចោទប្រកាន់ដោយសារតែពួកគេជាជនកុម្មុយនីស្ដ ជាជនសង្គមនិយម ឬជាជនបដិវត្តន៍នោះទេ។ បញ្ហាដែលពាក់ព័ន្ធមិនមែនថាតើ សំណុំរឿង០០២/០១ ជាតំណាងឲ្យគោលបំណងនយោបាយទាំងមូល ឬគោលនយោបាយនានារបស់ បកក នោះឡើយ។ ផ្ទុយទៅវិញ គឺជារឿងថាតើវិសាលភាពនៃការជំនុំជម្រះក្ដី តំណាងឲ្យឧក្រិដ្ឋកម្មក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះនៃសំណុំរឿង០០២ ដែរឬអត់។ មេធាវីការពារក្ដីមិនអាចតវ៉ាឲ្យជឿបានថា បទឧក្រិដ្ឋស្នូលដែលបានចោទប្រកាន់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ គឺការឃុំឃាំងដោយខុសច្បាប់ ការធ្វើទារុណកម្ម និងការសម្លាប់ពលរដ្ឋកម្ពុជានៅមន្ទីរសន្តិសុខទាំង១១ បានដាក់បញ្ចូលទៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះនោះទេ។ លើសពីនេះ ដោយមានការអះអាងខុសថា សហព្រះរាជអាជ្ញាបានផ្លាស់ប្ដូរការរៀបរាប់របស់ខ្លួនចំពោះលក្ខណៈជាមូលដ្ឋាននៃសំណុំរឿង០០២នោះ មេធាវីការពារក្ដីបានលុបចោលសេចក្ដីថ្លែងការណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ដែលបានធ្វើនៅក្នុងអំឡុងពេលនៃសវនាការបំបែកកិច្ចដំណើរការនីតិវិធី កាលពីខែកុម្ភៈ ឆ្នាំ២០១៣ ដូច្នេះថា៖

[74] **E284/4/1** បណ្ដឹងសាទុក្ខភ្លាមៗរបស់ នួន ជា, កំណត់សម្គាល់*ខាងដើម* លេខ២ ត្រង់កថាខណ្ឌទី៦១។

[75] **E284/2/1** សេចក្ដីសម្រេចលើបណ្ដឹងសាទុក្ខលើកទីពីររបស់សហព្រះរាជអាជ្ញា, កំណត់សម្គាល់*ខាងដើម* លេខ៥ ត្រង់កថាខណ្ឌទី៣៥-៣៦។

[76] **E284/4/1** បណ្ដឹងសាទុក្ខភ្លាមៗរបស់ នួន ជា, កំណត់សម្គាល់*ខាងដើម* លេខ២ ត្រង់កថាខណ្ឌទី៦២-៦៤។

"ក្នុងការសន្និដ្ឋានចុងក្រោយលើបញ្ហាស្ដីពីភាពជាតំណាងនេះ ករណីនេះ បេះដូងនៃករណីនេះ ទោះបីជាមានឧក្រិដ្ឋកម្មជាច្រើនត្រូវបានប្រព្រឹត្តនៅក្នុងសម័យកាលនេះក៏ដោយ ក៏បេះដូងនៃករណីនេះ គឺអំពីការចាប់ខ្លួន ការធ្វើទារុណកម្ម និងអំពីធ្វើមនុស្សឃាតនៅតាមបណ្ដាមន្ទីរសន្តិសុខនានា"[77]។ ដូចបានទទួលស្គាល់នៅក្នុងបណ្ដឹងសាទុក្ខនេះ សាក្សីជំនាញ Philip Short បានផ្ដល់សក្ខីកម្មថា ស-២១ គឺជាការឆ្លុះបញ្ចាំងឲ្យឃើញពីទម្រង់នៃការប្រមូលផ្ដុំមួយដែលមានលក្ខណៈទាសភាពដែល បកក បានបង្កើតឡើង។ ស-២១ ស្ថិតក្នុងលំដាប់ស្ថានភាពទាសភាពខ្ពស់ជាងគេ និងជាកន្លែងដែលសេរីភាពត្រូវបានបំបាត់ចោលទាំងស្រុង ដូចជាសេរីភាពក្នុងការរស់រានមានជីវិត"[78]។

២៦- ដោយសារមូលហេតុទាំងអស់នេះ សហព្រះរាជអាជ្ញាបញ្ជាក់អះអាងឡើងវិញអំពីគោលជំហររបស់ខ្លួនថា ស-២១ គឺជាទីតាំងឧក្រិដ្ឋកម្មដែលតំណាង ឆ្លុះបញ្ចាំងអំពីគោលនយោបាយធំទូលាយរបស់ បកក ក្នុងការកំណត់គោលដៅ និងកម្ទេចខ្មាំងរបស់ខ្លួន និងដោយសារមូលហេតុនេះ ទើបថាការដាក់បញ្ចូល ស-២១ គឺជាការសំខាន់ខ្លាំងដើម្បីឲ្យសំណុំរឿង ០០២/០១ បានធ្វើតំណាងឲ្យដីកាបញ្ជូនរឿងទៅជំនុំជម្រះ។ ការដាក់បញ្ចូល ស-២១ នឹងផ្ដល់ឱកាសដល់មេធាវីការពារក្ដីដែលពួកគេស្វែងរកដើម្បីកំណត់ថា នួន ជា "មិនបានសម្លាប់ពលរដ្ឋជាសហសេវិករបស់គាត់ដោយគិតទុកជាមុន"[79]ឡើយ។ ជនរងគ្រោះនៃ ស-២១ រួមមាន មនុស្សដែលធ្លាប់អង្គុយនៅតុជាមួយ នួន ជា ក្នុងកិច្ចប្រជុំនានារបស់គណៈកម្មាធិការអចិន្ត្រៃយ៍ និងគណៈកម្មាធិការមជ្ឈិម។ បើសិនជា នួន ជា ពិតជាមានបំណងចង់តតាំងនឹងបទចោទ ដែលគាត់មានការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ ចំពោះការធ្វើមនុស្សឃាតមែន នោះស-២១គឺជាទីតាំងដែលនឹងបំរើឲ្យគោលបំណងនេះបានយ៉ាងល្អបំផុត។

### ឃ. បទចោទបន្ថែមពាក់ព័ន្ធនឹងទីតាំងឧក្រិដ្ឋកម្មនៅមន្ទីរ ស-២១ មិននាំឲ្យមានភាពស្មុគស្មាញទេ ប៉ុន្តែមានសមត្ថភាព

[77] **E1/171.1** ប្រតិចារឹក, ១៨ កុម្ភៈ ២០១៣ ត្រង់ទំព័រទី៥៦, បន្ទាត់ទី២០-២៤។

[78] **E1/191.1** ប្រតិចារឹក, ៨ ឧសភា ២០១៣ ត្រង់ទំព័រទី៩, បន្ទាត់ទី២-២១ សូមមើលឯកសារលេខ **E284/4/1** បណ្ដឹងសាទុក្ខភ្លាមៗរបស់ នួន ជា, កំណត់សម្គាល់*ខាងដើម* លេខ១ ត្រង់កថាខណ្ឌទី៦៨។

[79] **E284/4/1** បណ្ដឹងសាទុក្ខភ្លាមៗរបស់ នួន ជា, កំណត់សម្គាល់*ខាងដើម* លេខ២ ត្រង់កថាខណ្ឌទី៤១។

២៧- ក្រុមមេធាវីការពារក្តីអះអាងដោយគ្មានភ័ស្តុតាងបញ្ជាក់ថា បទចោទបន្ថែមពាក់ព័ន្ធនឹង ស-២១ នឹងនាំឱ្យមានភាព"ស្មុគស្មាញ"[80]។ ជាការឆ្លើយតប សហព្រះរាជអាជ្ញាដាក់សេចក្តីសន្និដ្ឋានចំនួនបី។ ទីមួយ ការលើកឡើងបែបនេះ គឺផ្ទុយទៅនឹងជំហររបស់ក្រុមមេធាវីការពារក្តី ដែលអះអាងថាវិសាលភាពធំទូលាយជាងនេះក្នុងសំណុំរឿង០០២/០១ "អាចធ្វើទៅបាន និងចាំបាច់ថែមទៀតផង"។ មិនតែប៉ុណ្ណោះ ក្រុមមេធាវីការពារក្តីបានថែមទាំងស្នើសុំពង្រីកវិសាលភាពនៃការជំនុំជម្រះក្តីនេះ ធំលើសអ្វីដែលសហព្រះរាជអាជ្ញាស្នើសុំទៀតផង[81]។

២៨- ទីពីរ គួរសម្គាល់ថា ក្រុមមេធាវីការពារក្តីបានចំណាយពេល ២ ថ្ងៃកន្លះ ក្នុងសវនាការ ដើម្បីសួរដេញដោល ឌុច អំពីបញ្ហាអង្គហេតុដែលខ្លួនកំណត់ថាជាចំណុចស្នូលនៃមន្ទីរ ស-២១ រួចហើយ ដោយរួមបញ្ចូលទាំងការចោទប្រកាន់ស្តីពីការទទួលខុសត្រូវចំពោះមន្ទីរ ស-២១ របស់ នួន ជា និងអំពីថាតើ សុន សេន បន្តបំពេញតួនាទីនៅមន្ទីរ ស-២១ នេះយ៉ាងណា នៅបន្ទាប់ពីការចាកចេញពីទីក្រុងភ្នំពេញរបស់គាត់ កាលពីខែសីហា ឆ្នាំ១៩៧៧[82]។

២៩- ទីបី សហព្រះរាជអាជ្ញាយល់ស្របជាមួយក្រុមមេធាវីការពារក្តី ថាអ្នកយាមមន្ទីរ ស-២១ មួយចំនួន និងអ្នកសួរចម្លើយគួរកោះហៅមកធ្វើសក្ខីកម្ម ហើយក្រុមមេធាវីការពារក្តីគឺជាអ្នកត្រូវសួរសំណួរសាក្សីទាំងអស់នោះ ពាក់ព័ន្ធនឹងបញ្ហាដូចជា តួនាទីរបស់ សុន សេន អំណាចរបស់ ឌុច និងការប្រព្រឹត្តិមកលើឈ្លើយសឹកវៀតណាម។ កម្មាភិបាលមន្ទីរ ស-២១ បីរូប ក្នុងចំណោមអ្នកទាំងនោះ ត្រូវបានដាក់បញ្ចូលក្នុងចំណោមសាក្សីប្រាំរូប ដែលស្នើឡើងដោយសហព្រះរាអាជ្ញា និងយល់ស្របដោយក្រុមមេធាវីការពារក្តី។ បណ្តឹងសាទុក្ខគ្រាន់តែបញ្ជាក់អត្តសញ្ញាណសាក្សីបន្ថែម ៦ រូបដែលអាចកោះហៅ ជាអ្នកយាមមន្ទីរ ស-២១ ឬអ្នកសួរចម្លើយ ដែលសក្ខីកម្មរបស់ខ្លួនត្រូវបានក្រុមមេធាវីការពារក្តីអះអាងថាអាចមានសារៈសំខាន់។ សាក្សីទាំងនោះរួមមាន TCW-470, TCW-367, TCW-

---

[80] ឯកសារ E284/4/1 ដូចគ្នាខាងលើត្រង់កថាខណ្ឌ ៧៥-៨៣

[81] ឯកសារ E284/4/1 ដូចគ្នាខាងលើត្រង់កថាខណ្ឌ ៣១, ៣៤-៣៧

[82] សូមមើលឯកសារ **E1/58.1** ប្រតិចារឹក, ថ្ងៃទី ៣ ខែ មេសា ឆ្នាំ ២០១២, ឯកសារ **E1/59.1** ប្រតិចារឹក, ថ្ងៃទី ៤ ខែ មេសា ឆ្នាំ ២០១២, ឯកសារ **E1/60.1** ប្រតិចារឹក, ថ្ងៃទី ៥ ខែ មេសា ឆ្នាំ ២០១២, ឯកសារ **E1/62.1** ប្រតិចារឹក, ថ្ងៃទី ១០ ខែ មេសា ឆ្នាំ ២០១២។

598, TCW-410, TCW-474 និង TCW-512[83]។ សហព្រះរាជអាជ្ញាមិនយល់ស្របលើភាពពាក់ព័ន្ធ តម្លៃភ័ស្តុតាង ឬភាពចាំបាច់នៃសក្ខីកម្មរបស់សាក្សីទាំងនេះនោះទេ។ ប៉ុន្តែ ខ្លួនបានកត់សម្គាល់ថា ប្រសិនបើអង្គជំនុំជម្រះត្រូវការកោះហៅ ដើម្បីស្តាប់សក្ខីកម្មរបស់ពួកគាត់មែន សក្ខីកម្មពួកគាត់នឹងអាចប្រព្រឹត្តទៅក្នុងរយៈពេលប៉ុន្មានថ្ងៃ។

៣០- យោងតាមកាលៈទេសៈទាំងអស់នេះ គេមិនអាចនិយាយថា"ភាពស្មុគស្មាញ" នឹងកើតមាន ប្រសិនបើអង្គជំនុំជម្រះសាលាដំបូងសម្រេចបញ្ចូលបទចោទដែលពាក់ព័ន្ធនឹងមន្ទីរ ស-២១ នោះទេ។ បើប្រៀបធៀបទៅនឹងបទចោទនៃអំពើប្រល័យពូជសាសន៍ដែលក្រុមមេធាវីការពារក្តីស្នើសុំដាក់បន្ថែម ការជំនុំជម្រះក្តីពាក់ព័ន្ធនឹងមន្ទីរ ស-២១ ត្រូវការចំនួនសាក្សីបន្ថែមតិចតួចប៉ុណ្ណោះ ត្បិត(ពាក់ព័ន្ធនឹងអង្គហេតុមួយនេះ គ្រាន់តែខាងសហព្រះរាជអាជ្ញាប៉ុណ្ណោះ បានស្នើសុំអង្គជំនុំជម្រះសាលាដំបូងកោះហៅសាក្សីចំនួនដល់ទៅ ៤២ នាក់ទៅហើយ)[84]។ សក្ខីកម្មរបស់សាក្សីជាច្រើន[85] រួមទាំងភ័ស្តុតាងជាឯកសារ[86]

---

[83] ឯកសារ **E284/4/1** បណ្តឹងសាទុក្ខភ្លាមៗរបស់ នួន ជា, ត្រង់ចំណុច ២ ខាងលើ នៅកថាខណ្ឌ ៧៧ លេខចុងទំព័រ ១៥៩, កថាខណ្ឌ ៧៩ លេខចុងទំព័រ ១៦២, កថាខណ្ឌ ៨១ លេខចុងទំព័រ ១៦៥។

[84] ឯកសារ **E9/4.1** ឧបសម្ព័ន្ធ ១៖ លំដាប់លំដោយសាក្សីដែលត្រូវធ្វើសក្ខីកម្មនៅក្នុងសវនាការ (តបទៅនឹង"សេចក្តីណែនាំស្តីពីការស្នើសុំដាក់សារណាជាលាយលក្ខណ៍អក្សរអំពីអញ្ញត្រកម្ម" (E9/4)), ថ្ងៃទី ២០ ខែ មេសា ឆ្នាំ ២០០៩។ វិធាន ៨០ នៃវិធានផ្ទៃក្នុងនេះ បញ្ជីសាក្សីមានបញ្ចូលចំនួនសាក្សីសរុប ៤២ នាក់ ពាក់ព័ន្ធនឹងការប្រព្រឹត្តមកលើជនជាតិចាម និង វៀតណាម។

[85] សូមមើលឯកសារ **E284/2/1** បណ្តឹងសាទុក្ខទីពីររបស់សហព្រះរាជអាជ្ញា, ដូចចំណុច ៥ ខាងលើ ត្រង់កថាខណ្ឌ ៧៨។ ឯកសារ **E163/5/1/1.2** ឧបសម្ព័ន្ធ ១៖ តំណាងនៃគំរូភ័ស្តុតាងតាមរយៈសក្ខីកម្ម និង ឯកសារដែលបានបង្ហាញក្នុងសំណុំរឿង ០០២/០១ (តបទៅនឹង"បណ្តឹងសាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញា ពាក់ព័ន្ធនឹងសេចក្តីសម្រេចស្តីអំពីវិសាលភាពនៃការជំនុំជម្រះក្តីក្នុងសំណុំ រឿង ០០២/០១" ឯកសារ (E163/5/1/1)), ថ្ងៃទី ៧ ខែ វិច្ឆិកា ឆ្នាំ ២០១២។ ឯកសារ **E163/5/1/1** ឯកសារ បណ្តឹងសាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញា ពាក់ព័ន្ធនឹងសេចក្តីសម្រេចស្តីអំពីវិសាលភាពនៃការជំនុំជម្រះក្តីក្នុងសំណុំរឿង ០០២/០១, ថ្ងៃទី ៧ ខែ វិច្ឆិកា ឆ្នាំ ២០១២, កថាខណ្ឌ ៧៧-៨០។ ឯកសារ **E163/5/1/10** ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងចម្លើយតបរបស់ នួន ជា តបទៅនឹងបណ្តឹងសាទុក្ខលើសេចក្តីសម្រេចពាក់ព័ន្ធនឹងវិសាលភាពនៃការជំនុំជម្រះក្តីក្នុងសំណុំរឿង ០០២/០១, ថ្ងៃទី ៣ ខែ ធ្នូ ឆ្នាំ ២០១២, កថាខណ្ឌ ២៣។

[86] ឯកសារ **E185/1** សេចក្តីសម្រេចស្តីពីការជំទាស់ទៅនឹងការស្នើសុំដាក់ឯកសារនៅចំពោះមុខអង្គជំនុំជម្រះ នៅក្នុងឧបសម្ព័ន្ធ A៦-A១១ របស់សហព្រះរាជអាជ្ញា និង A១៤-A២០ និងដោយភាគីដទៃទៀត, ថ្ងៃទី ៣ ខែ ធ្នូ ឆ្នាំ ២០១២។ ឯកសារ **E185/1.3** សេចក្តីសម្រេចលើការជំទាស់ទៅនឹងការស្នើសុំដាក់ឯកសារនៅចំពោះអង្គជំនុំជម្រះ នៅក្នុងឧបសម្ព័ន្ធ A៦-A១១ របស់សហព្រះរាជអាជ្ញា និង A១៤-A២០ និងដោយភាគីដទៃទៀត៖ ឧបសម្ព័ន្ធ គ-ឯកសារដែលបានស្នើឡើងដោយសហព្រះរាជអាជ្ញា, ថ្ងៃទី៣ ខែធ្នូ ឆ្នាំ២០១២។

ពាក់ព័ន្ធនឹងនឹងមន្ទីរ ស-២១ បានបង្ហាញរួចមកហើយនៅសវនាការក្នុងសំណុំរឿង០០២/០១ ដូចបាន ទទួលស្គាល់ក្នុងសេចក្តីសម្រេចដែលរងការជំទាស់នេះ[87]។

ង. គេមិនត្រូវការឲ្យមានបទចោទបន្ថែមពាក់ព័ន្ធនឹងអំពើប្រល័យពូជសាសន៍ ដើម្បីបង្ហាញថាសំណុំរឿង ០០២/០១ មានលក្ខណៈតំណាងសមស្របនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះនោះទេ

៣១- សហព្រះរាជអាជ្ញាទទួលស្គាល់នូវភាពធ្ងន់ធ្ងរ នៃបទចោទពាក់ព័ន្ធនឹងអំពើប្រល័យពូជសាសន៍ ពាក់ព័ន្ធនឹងក្រុមជនជាតិចាម និងវៀតណាមនេះ ប៉ុន្តែ សូមបញ្ជាក់ថា បទចោទទាំងនោះគ្រាន់តែជាផ្នែកតូចមួយប៉ុណ្ណោះនៃគោលនយោបាយធំរួមនៃបក្សកុម្មុនីស្តកម្ពុជា ក្នុងការដៅជាលក្ខណៈប្រព័ន្ធទៅលើជនទាំងឡាយណាដែលចាត់ទុកថាជាសត្រូវរបស់របបនោះ។ មន្ទីរ ស-២១ គឺជាឧទាហរណ៍សំខាន់តែមួយគត់ ដែលមានលក្ខណៈតំណាងជាងគេនៃគោលនយោបាយធំរួមនោះ។

៣២- ដើម្បីរកយុត្តិធម៌ឲ្យបាននាប់រហ័ស សហព្រះរាជអាជ្ញាមានករណីយកិច្ច ក្នុងការស្នើសុំកុំឲ្យបញ្ចូលអំពើប្រល័យពូជសាសន៍ ទៅក្នុងវិសាលភាពនៃការជំនុំជម្រះក្តីក្នុងសំណុំរឿង០០២/០១។ លក្ខណៈវិនិច្ឆ័យនៃភាពសមហេតុផលមួយ គឺតម្រូវឲ្យយើងថ្លឹងថ្លែងនូវតុល្យភាពនៃប្រយោជន៍ផ្លូវច្បាប់៖ យើងត្រូវថ្លឹងថ្លែងវិសាលភាពនៃការជំនុំជម្រះក្តីដែលបានបំបែករួចមួយ ឲ្យស៊ីគ្នាទៅនឹងលទ្ធភាពដែលអាចសម្រេចបានយុត្តិធម៌នាប់រហ័ស។ បណ្តឹងសាទុក្ខមិនបានពិចារណា ឬវាយតម្លៃកត្តារាំងទាំងឡាយដែលជះផលអវិជ្ជមានដល់ការបញ្ចូលបទចោទទាំងអស់ ឬស្នើរតែទាំងអស់ចេញពីដីកាបញ្ជូនរឿងទៅជំនុំជម្រះក្នុងសំណុំរឿង០០២ នោះទេ។

៣៣- សហព្រះរាជអាជ្ញាបានវាយតម្លៃដូច្នេះរួចហើយ ដើម្បីបង្ហាញឲ្យឃើញនូវភាពសមហេតុសមផលនៃការបញ្ចូលមន្ទីរ ស-២១ ដោយកំណត់ចំនួនប៉ាន់ស្មាននៃសាក្សី និងចំនួនថ្ងៃធ្វើសវនាការដែលចាំបាច់[88]។ បទឧក្រិដ្ឋដែលបានប្រព្រឹត្តនៅមន្ទីរ ស-២១ ត្រូវបានកត់ត្រាទុកយ៉ាងហ្មត់ចត់ ហើយឯកសារទាំងនេះភាគច្រើន ត្រូវបានអង្គជំនុំជម្រះសាលាដំបូងទទួលស្គាល់ជាភ័ស្តុតាងរួចហើយ។ ដូច្នេះ ការពន្លាតវិសាលភាពនៃការជំនុំជម្រះក្តី ដើម្បីបញ្ចូលមន្ទីរ ស-២១ នឹងតម្រូវឲ្យមានសាក្សី

[87] ឯកសារ **E284** សេចក្តីសម្រេចដែលរងការជំទាស់ ត្រង់កថាខណ្ឌ ១១៧។

[88] ឯកសារ **E284/2/1** បណ្តឹងសាទុក្ខលើសេចក្តីសម្រេចលើកទីពីររបស់សហព្រះរាជអជ្ញា, ដូចចំណុច ៥ ខាងលើ ត្រង់កថាខណ្ឌ ៥១-៥៩។

បន្ថែមតិចតួចប៉ុណ្ណោះ។ ផ្ទុយទៅវិញ ជាពិសេសភ័ស្តុតាងនៃគោលនយោបាយរបស់បក្សកុម្មុនីស្តកម្ពុជាប្រឆាំងជនជាតិចាម ពឹងផ្អែកលើសាក្សី និងចម្លើយសាក្សីជាច្រើន ដែលពន្យល់អំពីបែបផែននៃការប្រព្រឹត្តិផ្ទាល់ទៅលើជនជាតិចាមនៅភូមិភាគផ្សេងៗគ្នា គឺវាស៊ីសង្វាក់គ្នាទៅនឹងគោលនយោបាយរួមមួយរបស់មជ្ឈិមបក្ស។ ដូចបានគូសបញ្ជាក់ខាងលើ កិច្ចដំណើរការនីតិវិធីដែលបូកបញ្ចូលទាំងបទចោទពាក់ព័ន្ធនឹងបទល្មើសនៃអំពើប្រល័យពូជសាសន៍ តម្រូវឲ្យមានសវនាការស្តាប់សាក្សីច្រើន(រួមទាំងសាក្សី ៤២ រូប ដែលស្នើឡើងដោយសហព្រះរាជអាជ្ញា) និងតម្រូវឲ្យធ្វើសវនាការជំនុំជម្រះក្តីច្រើនខែបន្ថែមទៀត។

៣៤- សហព្រះរាជអាជ្ញាកត់សម្គាល់បន្ថែមទៀតថា វិសាលភាពបច្ចុប្បន្ននៃសំណុំរឿង ០០២/០១ បញ្ចូលប្រជាជនចាមច្រើនរួចហើយ ក្នុងផ្នែកមួយនៃការជម្លៀសប្រជាជនដោយបង្ខំក្នុងតំណាក់កាលទីពីរ[89]។ លើសពីនេះទៅទៀត ការបញ្ចូលមន្ទីរ ស-២១ នឹងបូកចូលទាំងបទឧក្រិដ្ឋដែលបានប្រព្រឹត្តនៅទីតាំងនោះ ដែលប្រឆាំងទាំងជនជាតិវៀតណាមដែលរស់នៅប្រទេសកម្ពុជា និងទាហានវៀតណាម ជាឈ្លើយសឹកដែលត្រូវបានចាប់ខ្លួន និងបញ្ជូនទៅមន្ទីរ ស-២១[90]។ ដូច្នេះ ដើម្បីបង្ហាញឲ្យឃើញអំពីការប្រព្រឹត្តិមកលើក្រុមជនជាតិចាម និងវៀតណាម គេមិនចាំបាច់បញ្ចូលបទចោទពាក់ព័ន្ធនឹងអំពើប្រល័យពូជសាសន៍ ទៅក្នុងវិសាលភាពនៃសំណុំរឿង០០២/០១ នេះទេ។

៣៥- ក្រុមមេធាវីការពារក្តីបានលើកឡើងក្នុងសម្អាងហេតុរបស់ខ្លួនថា[91] ការបញ្ចូលមន្ទីរ ស-២១ អាចមានលក្ខណៈគ្រប់គ្រាន់ក្នុងការ "ពិចារណាអំពីការដឹងឮ និងចេតនារបស់ជនជាប់ចោទ" ពាក់ព័ន្ធទៅនឹងបទឧក្រិដ្ឋ (មិនមែនបទប្រល័យពូជសាសន៍) ប្រឆាំងក្រុមជនជាតិចាម និងវៀតណាម។ ជាពិសេសការបញ្ចូលមន្ទីរ ស-២១ គឺជាការដាក់ នួន ជា ឲ្យទទួលខុសត្រូវលើការធ្វើទុក្ខបុកម្នេញនៃបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិលើមនុស្សពីរក្រុមដូចគ្នានេះ។ ដូច្នេះ កាលណាក្រុមមេធាវីការពារក្តីស្នើសុំសេចក្តីសម្រេចតាមផ្លូវតុលាការស្តីពី "ការដឹងឮ និងចេតនា" របស់ជនជាប់ចោទពាក់ព័ន្ធនឹងការប្រព្រឹត្តិលើក្រុមដែលគេចាត់ទុកជាគោលដៅ មានន័យថាគេមិនចាំបាច់បញ្ចូលអំពើប្រល័យពូជសាសន៍ទៀតនោះទេ។ ក្នុងការសម្រេចលើធាតុផ្សំចេតនាសម្រាប់ការចោទប្រកាន់ តុលាការនឹងត្រូវរកឲ្យឃើញផងដែរ

[89] ឯកសារ **D427** ដីកាដំណោះស្រាយ, ដូចចំណុច ៧៤ ខាងលើ ត្រង់កថាខណ្ឌ ២៦៦, ២៦៨, ២៨១។

[90] ឯកសារ **E284/2/1** បណ្តឹងសាទុក្ខលើសេចក្តីសម្រេចលើកទីពីររបស់សហព្រះរាជអាជ្ញា, ដូចចំណុច ៥ ខាងលើ ត្រង់កថាខណ្ឌ ៣៨។

[91] ឯកសារ **E284/4/1** បណ្តឹងសាទុក្ខភ្លាមៗរបស់ នួន ជា, ដូចចំណុច ២ ខាងលើ ត្រង់កថាខណ្ឌ ៤៧។

ថាតើ នួន ជា ពិតជា "មានចេតនាជាក់លាក់ក្នុងការសម្លាប់ប្រជាជនខ្លួនឯង"[92] ដែរឬយ៉ាងណា ដែលផ្នែកនេះខាងក្រុមមេធាវីការពារក្តីហៅថា "ចំណុចស្នូលនៃបញ្ហាសំខាន់ និងមិនច្បាស់លាស់ដែលសាលាក្តីនេះត្រូវប្រឈម[93]"។

៣៦- លើសពីនេះទៅទៀត ចំនួនអ្នកស្លាប់ដែលជាជនជាតិចាម និងវៀតណាម ដែលក្រុមមេធាវីការពារក្តី[94] អះអាង គឺជាចំនួនអ្នកស្លាប់នៅទូទាំងប្រទេស មិនមែនជាចំនួនអ្នកស្លាប់ពាក់ព័ន្ធតែទីតាំងឧក្រិដ្ឋកម្មជាក់លាក់ក្នុងភូមិភាគកណ្តាល និងបូព៌ា ដែលត្រូវបានបញ្ចូលក្នុងបទចោទពាក់ព័ន្ធអំពើប្រល័យពូជសាសន៍ ក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះនោះឡើយ[95]។ ក្រុមមេធាវីការពារក្តីបានធ្វើមិនដឹងមិនឮចំពោះការសម្លាប់ទ្រង់ទ្រាយធំមកលើជនជាតិចាម និងវៀតណាម ដែលត្រូវបានចោទប្រកាន់ថាបានចាប់ផ្តើមនៅក្នុងឆ្នាំ១៩៧៧[96]។ ដូច្នេះ ក្រុមមេធាវីការពារក្តីមិនបានគិតគូទៅលើវិសាលភាពពេលវេលាទាំងមូលនៃរបបកម្ពុជាប្រជាធិបតេយ្យនោះទេ។ ប្រការនេះគឺវាផ្ទុយទៅនឹងអ្វីដែលខ្លួនបានអះអាងក្នុងកថាខណ្ឌ ៤៨(ឃ) នៅក្នុងបណ្តឹងសាទុក្ខ។

៣៧- ជាទីបញ្ចប់ នៅក្នុងសេចក្តីបន្ថែម ក្រុមមេធាវីការពារក្តីលើកឡើងថា ព្រឹត្តការណ៍ព័ត៌មានថ្មីៗដែលនាំឲ្យមាន "ច្បាប់ចាត់ទុកជាបទល្មើសព្រហ្មទណ្ឌចំពោះការមិនទទួលស្គាល់អំពើប្រល័យពូជសាសន៍" គាំទ្រដល់ជំហររបស់ខ្លួន ដែលអះអាងថាសវនាការក្នុងសំណុំរឿង០០២/០១ ត្រូវតែបញ្ចូលបទចោទពាក់ព័ន្ធនឹងអំពើប្រល័យពូជសាសន៍នេះ។ សហព្រះរាជអាជ្ញាបានទទួលដំណឹងថា ច្បាប់ស្តីពីការប្រឆាំងនឹងការមិនទទួលស្គាល់ឧក្រិដ្ឋកម្មប្រព្រឹត្តក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ដែលរដ្ឋសភាជាតិបានអនុម័ត គឺពុំមានចែងយោងទៅនឹងបទល្មើសនៃអំពើប្រល័យពូជសាសន៍ឡើយ។ មិនតែប៉ុណ្ណោះ ច្បាប់នេះពុំមែនកើតចេញពីការមិនទទួលស្គាល់អំពើប្រល័យពូជសាសន៍ប្រឆាំងជនជាតិចាម និងវៀតណាមនោះទេ ប៉ុន្តែវាកើតចេញពីសេចក្តីថ្លែងដែលបានរាយការណ៍សួរយថាភូតអំពីមន្ទីរសន្តិសុខ ស-២១។ ទោះយ៉ាងណាក៏ដោយ បញ្ហានៅចំពោះអង្គជំនុំជម្រះនេះពាក់ព័ន្ធតែទៅលើវិសាលភាពនៃការជំនុំជម្រះនៅចំពោះអង្គជំនុំជម្រះសាលាដំបូងតែប៉ុណ្ណោះ ពោលគឺមិនពាក់ព័ន្ធនឹងការកាត់ក្តីតាមមតិ

---

[92] ឯកសារ E284/4/1 ដូចគ្នាខាងលើត្រង់កថាខណ្ឌ ៤២។ បើតាមស្ទាន មេធាវីការពារក្តីនៅទីនេះនិយាយសំដៅប្រជាជនចាមក្នុងរបបកម្ពុជាប្រជាធិបតេយ្យ និង អ្នកដែលមានដើមកំណើតវៀតណាម។

[93] ឯកសារ E284/4/1 ដូចគ្នាខាងលើ

[94] ឯកសារ E284/4/1 ដូចគ្នាខាងលើត្រង់កថាខណ្ឌ ៤៨(ខ)

[95] ឯកសារ **D427** ដីកាដំណោះស្រាយ, ដូចចំណុច ៧៤ ខាងលើ ត្រង់កថាខណ្ឌ ៧៦៣, ៧៧១-៧៨៩, ៧៩៧-៨០១។

[96] ឯកសារ **D427** ដូចគ្នាខាងលើ ត្រង់កថាខណ្ឌ ៧៦៣, ៧៩៧។

សាធារណៈនោះឡើយ។ ការពិចារណាដែលមេធាវីការពារក្តីបានលើកឡើងក្នុងសេចក្តីបន្ថែម គឺជាចំណុចមិនចាំបាច់ និងឥតពាក់ព័ន្ធអ្វីទាំងអស់ ក្នុងការសម្រេចអំពីខ្លឹមសារនៃបណ្តឹងសាទុក្ខនេះ។

ច. មិនចាំបាច់មានបទចោទបន្ថែមពាក់ព័ន្ធនឹងការដ្ឋានពលកម្ម និងសហករណ៍ទេ

៣៨- ក្រុមមេធាវីការពារក្តីលើកឡើងថា ជាការចាំបាច់គេត្រូវបញ្ចូលបទឧក្រិដ្ឋដែលបានប្រព្រឹត្តនៅតាមសហករណ៍ ឬការដ្ឋានពលកម្ម ដើម្បីឲ្យ នួន ជា មានឱកាសបំភ្លឺទៅនឹងបញ្ហានៃ"សមូហភាវូបនីយកម្មដោយបង្ខំ"[97]នេះ។ ទោះជាយ៉ាងនេះក្តី បញ្ហានេះបានក្លាយជាផ្នែកមួយនៃសំណុំរឿង០០២/០១ រួចទៅហើយ។ ក្រុមមេធាវីការពារក្តីខ្លួនឯងក៏បានទទួលស្គាល់ផងដែរ[98] ថាគោលបំណងមួយក្នុងចំណោមគោលបំណងច្រើនទៀតនៃការជម្លៀសដោយបង្ខំ ជាពិសេសក្នុងដំណាក់កាលទីពីរ គឺដើម្បីជម្លៀសប្រជាជនទៅកាន់សហករណ៍[99]។ ដូច្នេះ សហព្រះរាជអាជ្ញាបញ្ជាក់ថា គេមិនចាំបាច់បញ្ចូលសហករណ៍ និងការដ្ឋានជាក់លាក់ណាមួយ ដើម្បីបំពេញលក្ខខណ្ឌតម្រូវនៃភាពតំណាងសមស្របពាក់ព័ន្ធនឹងប្រភេទនៃទីតាំងឧក្រិដ្ឋកម្មមួយនេះនោះទេ។

៣៩- ផ្ទុយទៅវិញ ស្របពេលដែលដីកាបញ្ជូនរឿងទៅជំនុំជម្រះក្នុងសំណុំរឿង០០២ មានបញ្ចូលមន្ទីរសន្តិសុខចំនួន ១១ កន្លែងយ៉ាងណាក្តី ក៏គ្មានមន្ទីរសន្តិសុខណាមួយ ត្រូវបានតំណាងក្នុងវិសាលភាពនៃសំណុំរឿង០០២/០១ នេះនោះឡើយ។ ជារួម មន្ទីរសន្តិសុខគឺតំណាងឲ្យប្រភេទទីតាំងនៃបទឧក្រិដ្ឋទូទៅ ដែលមានចែងនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ។ មន្ទីរសន្តិសុខទាំង១១ កន្លែង ដែលមានបញ្ចូលក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ គឺជាផ្នែកនៃបណ្តាញទូទាំងប្រទេស ដោយក្នុងនោះមន្ទីរ ស-២១ គឺជាចំណុចកំពូលនៃរចនាសម្ព័ន្ធសន្តិសុខនោះ។ ដូចគ្នានេះផងដែរ គោលបំណងរបស់ការដ្ឋាន និងសហករណ៍ ដែលត្រូវបានបញ្ចូលក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ គឺមានលក្ខណៈមិនខុសគ្នា ឬដូចគ្នាជាទូទៅ។ មួយគឺជាការដ្ឋានលត់ដំដែលជាផ្នែកនៃមន្ទីរ ស-២១[100]។ ឯមួយទៀត គឺជាទីកន្លែងលត់ដំ ដែលឃោធាប្រើសម្រាប់ទាហានដែលចាត់ទុកថាជា "សមាសភាពមិនល្អ" ដែលអ្នកទាំងនោះភាគ

---

[97] ឯកសារ **E284/4/1** បណ្តឹងសាទុក្ខភ្លាមៗរបស់ នួន ជា, ដូចចំណុច ២ ខាងលើ ត្រង់កថាខណ្ឌ ៥០-៥២។

[98] ឯកសារ **E284/4/1** ដូចគ្នាខាងលើត្រង់កថាខណ្ឌ ១៥។

[99] ឯកសារ **D427** ដីកាដំណោះស្រាយ, ដូចចំណុច ៧៤ ខាងលើត្រង់កថាខណ្ឌ ១៦១, ២៧៦-២៧៧។

[100] ឯកសារ **D427** ដូចគ្នាខាងលើ ត្រង់កថាខណ្ឌ ៤០០។

ច្រើនត្រូវបានបញ្ជូនទៅកាន់ ស-២១[101]។ ដីកាបញ្ជូនរឿងទៅជំនុំជម្រះក្នុងសំណុំរឿង០០២ ក៏មានបញ្ចូលស្រែអំបិល[102] និងការដ្ឋានចំនួនពីរ ដែលមានការងារសង់ទំនប់ផងដែរ[103]។ ដីកាបញ្ជូនរឿងទៅជំនុំជម្រះគ្រាន់តែបញ្ចូលទីតាំងឧក្រិដ្ឋកម្មមួយប៉ុណ្ណោះ ដែលអាចចាត់ទុកបានថាជា "សហករណ៍" មួយ[104]។ ដូច្នេះ ក្រុមមេធាវីការពារក្ដីមិនអាចលើកឡើងថា បទឧក្រិដ្ឋនៅសហករណ៍ គឺតំណាងឲ្យ "ប្រភេទ ឬលក្ខណៈមូលដ្ឋាននៃសំណុំរឿងនេះ"បាននោះទេ[105]។ ប្រសិនបើអង្គជំនុំជម្រះនេះយល់ឃើញថា ខ្លួនចាំបាច់ត្រូវបញ្ចូលការដ្ឋានណាមួយ ដើម្បីឲ្យការជំនុំជម្រះក្ដីក្នុងសំណុំរឿង០០២/០១ មានលក្ខណៈតំណាងសមស្របនោះ នោះអង្គជំនុំជម្រះគ្រាន់តែបញ្ចូលការដ្ឋានមួយដែលជាផ្នែកនៃ ស-២១ គឺមានលក្ខណៈតំណាងគ្រប់គ្រាន់ទៅហើយ[106]។

៤០- នៅទីបញ្ចប់ ស្របពេលដែលក្រុមមេធាវីការពារក្ដីអះអាងថា សហករណ៍ និងការដ្ឋាន ប៉ះពាល់ជារួមដល់ជនរងគ្រោះជាច្រើន និងកើតមាននៅពាសពេញប្រទេសក្នុងអំឡុងនៃរបបកម្ពុជាប្រជាធិបតេយ្យ[107] បញ្ហាដែលពាក់ព័ន្ធគឺជាវិសាលភាពនៃទីតាំងភូមិសាស្ត្រ វិសាលភាពនៃពេលវេលា និងជនរងគ្រោះពាក់ព័ន្ធនឹងទីតាំងឧក្រិដ្ឋកម្មជាក់លាក់ឯណោះទៅវិញទេ ដែលត្រូវគិតបញ្ចូលនៅក្នុងការជំនុំជម្រះក្ដីក្នុងសំណុំរឿង០០២/០១។ វិសាលភាពពិតប្រាកដនៃទីតាំងភូមិសាស្ត្រ និងពេលវេលាពាក់ព័ន្ធនឹងទីតាំងឧក្រិដ្ឋកម្មផ្សេងៗគ្នាទាំងអស់នេះ គឺកម្រិតច្រើនជាងអ្វីដែលមេធាវីការពារក្ដីបានស្នើសុំ។

### ឆ. ដំណោះស្រាយសមស្របគឺមានតែការធ្វើវិសោធនកម្ម មិនមែនការធ្វើមោឃភាពសេចក្ដីសម្រេចដែលរងការជំទាស់នោះទេ

៤១- ក្រុមមេធាវីការពារក្ដីស្នើសុំឲ្យ"អនុវត្តតាមវិធីដែលសាមញ្ញបំផុត និងដោយគ្មានការប្រឆាំង" ពោលគឺត្រូវធ្វើមោឃភាពសេចក្ដីសម្រេចដែលរងការជំទាស់ និងដែល"រារាំងដល់ការបំបែកសំណុំរឿងជាថ្មី"

---

[101] ឯកសារ **D427** ដូចគ្នាខាងលើ ត្រង់កថាខណ្ឌ ៣៨៧, ៣៨៩, ៣៩៦។

[102] ឯកសារ **D427** ដូចគ្នាខាងលើ ត្រង់កថាខណ្ឌ ៣៦៩-៣៨១

[103] ឯកសារ **D427** ដូចគ្នាខាងលើ ត្រង់កថាខណ្ឌ ៣២៣-៣៤៩, ៣៥១-៣៦៧។

[104] ឯកសារ **D427** ដូចគ្នាខាងលើ ត្រង់កថាខណ្ឌ ៣០២-៣២១។

[105] ឯកសារ **E284/4/1** បណ្ដឹងសាទុក្ខភ្លាមៗរបស់ នួន ជា, ដូចចំណុច ២ ខាងលើ ត្រង់កថាខណ្ឌ ៥១។

[106] ឯកសារ **D427** ដីកាដំណោះស្រាយ, ដូចចំណុច ៧៤ ខាងលើ ត្រង់កថាខណ្ឌ ៤០០-៤១៣។

[107] ឯកសារ **E284/4/1** បណ្ដឹងសាទុក្ខភ្លាមៗរបស់ នួន ជា, ដូចចំណុច ២ ខាងលើ ត្រង់កថាខណ្ឌ ៥៤-៥៥។

នោះ[108]។ ទន្ទឹមនឹងនេះ ពួកគេបានស្នើសុំឲ្យអង្គជំនុំជម្រះចេញដីកាបង្គាប់ឲ្យដាក់បញ្ចូលបទចោទពាក់ព័ន្ធនឹងអំពើប្រល័យពូជសាសន៍ និងការដ្ឋាន ឬសហករណ៍ចូលទៅក្នុង "វិសាលភាពទូលំទូលាយនៃសំណុំរឿង០០២/០១ ដែលទំនងជាទទួលផ្លែផ្កាច្រើនជាងការជំនុំជម្រះលើកទីពីរ នៅក្នុងសំណុំរឿង០០២/០២"[109]។ ក្រុមមេធាវីការពារក្តីពុំបានផ្តល់មូលដ្ឋានអង្គហេតុត្រឹមត្រូវ ដើម្បីបញ្ជាក់មូលហេតុអ្វីបានជាអង្គជំនុំជម្រះតុលាការកំពូលអាចវាយតម្លៃថាគេអាចបញ្ចប់ការជំនុំជម្រះក្តី ក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះទាំងមូលនៅថ្ងៃអនាគត ឬមូលហេតុអ្វីបានជាការស្នើឲ្យតុលាការជំនុំជម្រះក្តីតែលើអង្គហេតុកំណត់មួយចំនួន រួមទាំងបទចោទពាក់ព័ន្ធនឹងអំពើប្រល័យពូជសាសន៍ និងការដ្ឋាន/ សហករណ៍ ក្រៅតែពីអះអាងថាការជំនុំជម្រះក្តីនេះគឺពិតអាចធ្វើបាន និងមានលក្ខណៈចាំបាច់[110] និងគេមិនអាចទស្សន៍ទាយជាមុនបានថា នួន ជា អាចរស់យូរបានប៉ុនណា"[111] នោះទេ។

៤២- ជាការពិតណាស់ គ្មាននរណាអាចទាយដឹងថាមនុស្សម្នាក់អាចរស់យូរប៉ុនណាទេ។ ប៉ុន្តែ អាយុកាលជាមធ្យមនៃប្រជាពលរដ្ឋទូទៅ គឺនៅតែជាទិន្នន័យជាក់លាក់ផ្នែកវិទ្យាសាស្ត្រពិតមួយ ដែលតុលាការទាំងឡាយអាចយកមកពិចារណា ដើម្បីទាញសេចក្តីសន្និដ្ឋាន និងចេញសេចក្តីសម្រេចនានាបាន[112]។ កន្លងមក ក្រុមមេធាវីការពារក្តីបានអះអាងទាំងមិនច្បាស់លាស់ នៅពេលខ្លួនយល់ស្របថា ថ្ងៃខាងមុខនៃការជំនុំជម្រះក្តីបន្ថែមប្រឆាំងជនជាប់ចោទ គឺពុំមានអ្វីច្បាស់ប្រាកដនោះទេ៖ "ខ្ញុំយល់ថា ចាប់ពីពេលនេះតទៅ យើងគួរឈប់នឹកនាដល់លទ្ធភាពនៃការជំនុំជម្រះក្តីណាមួយទៀត នៅក្នុងសំណុំរឿង០០២ នេះទៅ ដ្បិតវាច្បាស់ណាស់ទៅហើយ ថាឥឡូវនេះយើងកំពុងតែជាប់គាំងក្នុងសំណុំរឿង០០២/០១ ទៅមុខមិនរួចផង។ ដូច្នេះ គ្មានការជំនុំជម្រះក្តីផ្សេងឯណាទៀត អាចប្រព្រឹត្តទៅបានទេ។ ខ្ញុំជឿថារឿងនេះនរណាក៏យល់ឃើញដូច្នេះដែរ"[113]។

---

[108] ឯកសារ **E284/4/1** ដូចគ្នាខាងលើ ត្រង់កថាខណ្ឌ ២៥។

[109] ឯកសារ **E284/4/1** ដូចខាងលើ ត្រង់កថាខណ្ឌ ៣៥។

[110] ឯកសារ **E284/4/1** ដូចខាងលើ ត្រង់កថាខណ្ឌ ៣១។

[111] ឯកសារ **E284/4/1** ដូចខាងលើ ត្រង់កថាខណ្ឌ ២៩។

[112] ឯកសារ **E284/2/1** បណ្តឹងសាទុក្ខលើសេចក្តីសម្រេចលើកទី២របស់សហព្រះរាជអាជ្ញា, ដូចចំណុច ៥ ខាងលើ ត្រង់កថាខណ្ឌ ៦៤-៦៥។

[113] ឯកសារ **E1/136.1** ប្រតិចារឹក, ថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០១២ ត្រង់ទំព័រទី ៩ បន្ទាត់ ៣-១១។ សូមមើលផងដែរ ឯកសារ **E1/114.2** ប្រតិចារិក, ថ្ងៃទី ២៧ ខែ សីហា ឆ្នាំ ២០១២ ត្រង់ទំព័រ ២៤-២៥។ ឯកសារ **E1/135.1** ប្រតិចារិក, ថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០១២ ត្រង់ទំព័រទី ៤២។

៤៣- សហព្រះរាជអាជ្ញាស្នើសុំឲ្យធ្វើវិសោធនកម្មសេចក្តីសម្រេចដែលរងការជំទាស់ ជាជាងធ្វើមោឃភាព និងបានផ្តល់សេចក្តីពន្យល់អំពីការប្រមើលឃើញច្បាស់ប្រាកដនានា ដើម្បីជួយដល់អង្គជំនុំជម្រះក្នុងការវាយតម្លៃភាពសមហេតុសមផលនៃការស្នើដាក់បញ្ចូល ស-២១ នេះ[114]។ តាំងតែពីដើមដំបូងមកម្ល៉េះ ការបង្វិលបញ្ហានេះទៅអង្គជំនុំជម្រះដើម្បីសម្រេចរហូតដល់បីដងគិតទាំងលើកនេះ គឺជាការមិនសមហេតុផលទេ ត្បិតការធ្វើដូច្នេះគឺផ្ទុយទៅនឹងសេចក្តីណែនាំរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីការបំបែកសំណុំរឿង និងនាំឲ្យប៉ះពាល់ដល់ការអូសបន្លាយនីតិវិធីឥតការ។ អង្គជំនុំជម្រះនេះបានពិចារណាយ៉ាងល្អិតល្អន់ក្នុងពេលសម្រេចបំបែកសំណុំរឿងដែលពាក់ព័ន្ធទាំងនេះ។ អង្គជំនុំជម្រះសាលាដំបូងផ្ទាល់បានទទួលស្គាល់ "យុត្តាធិការនៃការកែតម្រូវ" របស់អង្គជំនុំជម្រះនេះដែលបង្គាប់ឲ្យអង្គជំនុំជម្រះសាលាដំបូង "បូកបន្ថែមស-២១"[115]។ ក្នុងដំណាក់កាលជិតចប់សវនាការបែបនេះ គេគប្បីអនុវត្តយុត្តាធិការនៃការកែតម្រូវដូច្នេះ ក្នុងលក្ខណៈត្រង់ផ្ទាល់បំផុត និងបង្កការរំខានតិចតួច និងជាក់ស្តែង តាមរយៈការគិតគូត្រង់ ជាពិសេសទៅលើ ស-២១ និងទីតាំងសម្លាប់មនុស្សដែលពាក់ព័ន្ធដទៃទៀតក្នុងវិសាលភាពនៃការជំនុំជម្រះក្តីសំណុំរឿង០០២/០១ នេះ។

## V. ដំណោះស្រាយ

៤៤- អាស្រ័យដូចបានរៀបរាប់ជូនខាងលើ សហព្រះរាជអាជ្ញាស្នើសុំអង្គជំនុំជម្រះតុលាការកំពូល៖

ក) **បដិសេធ** បណ្តឹងសាទុក្ខលើខ្លឹមសារនេះ

---

[114] ឯកសារ **E284/2/1** បណ្តឹងសាទុក្ខលើសេចក្តីសម្រេចលើកទី២របស់សហព្រះរាជអាជ្ញា, ដូចចំណុច ៥ ខាងលើ ត្រង់កថាខណ្ឌ ៥១-៧៥។

[115] ឯកសារ **E284** សេចក្តីសម្រេចដែលរងការជំទាស់ ត្រង់កថាខណ្ឌ ៩៥។

ខ) **តម្កល់** បណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា និង**ធ្វើវិសោធនកម្ម** សេចក្តីសម្រេចដែលរងការជំទាស់ ដើម្បីដាក់បញ្ចូល **មន្ទីរសន្តិសុខស-២១** (រួមទាំងទីតាំងសម្លាប់មនុស្សនៅជើងឯក) ទៅក្នុងវិសាលភាពនៃការជំនុំជម្រះក្តី ក្នុងសំណុំរឿង០០២/០១។

| **កាលបរិច្ឆេទ** | **ឈ្មោះ** | **ទីកន្លែង** | **ហត្ថលេខា** |
|---|---|---|---|
| ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៣ | **លោកស្រី ជា លាង**<br>សហព្រះរាជអាជ្ញា | ភ្នំពេញ | [signature] |
| | **លោក** Andrew CAYLEY<br>សហព្រះរាជអាជ្ញា | | [signature] |